ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# សារៈសំខាន់ស្តង់ដាគណនេយ្យអន្តរជាតិ នៃកម្ពុជា ២

# THE IMPORTANCE OF CAMBODIAN INTERNATIONAL ACCOUNTING STANDARD 2 (CIAS 2)

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥
PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# សារៈសំខាន់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ២
# THE IMPORTANCE OF CAMBODIAN INTERNATIONAL ACCOUNTING STANDARD 2 (CIAS 2)

គ្រូណែនាំៈ គី សុភាក់

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥
PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**

**ប្រធានបទ៖ សារៈសំខាន់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ២**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

គី សុភាក់

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អំណរគុណ

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេស ក្រុមយើងខ្ញុំបានយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមួយមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការគណនេយ្យដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិត កាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យបានយល់ច្បាស់ពីការអនុវត្តការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតប ឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "សារៈសំខាន់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ២" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការធ្វើម៉ាឃីតធីង។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណាមួយនេះឡើង នឹងបានចូលរួមចំណែកមួយក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានគោលបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



ថៃ ណាវី
ID: B22/019



ម៉ន សុជាតា
ID: B22/106



សេង ហ្គិចហ័ង
ID: B22/068



ចេង សុខភាន
ID: B22/080



ស្រេង គឹម ហ៊ាង
ID: B22/089

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យា វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ **គី សុភាក់** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកនៃវិទ្យាស្ថានវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតដល់ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## អំណះអំណាង

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទស្ដីអំពី "សារៈសំខាន់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ២" នេះគឺពិតជាស្នាដៃមួយរបស់ក្រុមខ្ញុំបាទ នាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលដែលទាក់ទងទៅនឹងការស្រាវជ្រាវ ដែលបានលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ.ពុធ..៨កើត.. ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី២៩ ខែតុលាឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



ថៃ ណារី

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ដើម្បីបំពេញទៅតាមលក្ខខណ្ឌរបស់សាកលវិទ្យាល័យវ៉ាន់ដាគណនេយ្យអោយបានត្រឹមត្រូវ និងដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដែលបានសិក្សារយៈពេលពីរឆ្នាំកន្លងមកនេះ ដែលក្រុមរបស់ខ្ញុំក៏ជានិស្សិតដែលមានការជ្រោមជ្រែងយ៉ាងកក់ក្តៅពីលោកគ្រូអ្នកគ្រូសាស្ត្រាចារ្យ ដែលបានប្រមូលផ្តុំនូវចំណេះដឹងគ្រប់បែបយ៉ាងដែលបានផ្តល់មកគឺ ជាគោលបំណងយ៉ាងសំខាន់មួយ ការរៀបរៀងនូវការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី "សារៈសំខាន់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ២" បានធ្វើក្រុមរបស់យើងខ្ញុំបានសិក្សាជាច្រើនទៅស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ២បានយ៉ាងច្បាស់ជាងមុនទៅលើចំណុចសំខាន់ៗនៃស្តង់ដានេះ។ ដោយស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ២នេះបានបរិយាយយ៉ាងច្បាស់ទៅលើគ្រប់គ្រងទៅលើថ្លៃដើមនៃសិន្និ និងការប្រើប្រាស់រូបមន្តថ្លៃដើមនៃសិន្និ។

ក្រុមប្រឹក្សាជាតិគណនេយ្យដែលសព្វថ្ងៃត្រូវបានគេស្គាល់ថាជានិយ័តករគណនេយ្យនិងសវនកម្មគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានពាំនាំមកនូវស្តង់ដាគណនេយ្យអន្តរជាតិបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន។ ដោយផ្អែកលើការសិក្សាស្រាវជ្រាវបានឃើញនៅមានចំណុចជាច្រើនដែលស្តង់ដានេះបានផ្តល់អត្ថប្រយោជន៍ និងសារៈសំខាន់ចំពោះការអនុវត្តនឹងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់គណនេយ្យករ ឬស្ថាប័នស្វែងរកប្រាក់ចំណេញមួយចំនួនដូចជា ក្រុមហ៊ុនផ្តល់សេវាកម្ម ក្រុមហ៊ុនផលិតកម្ម និងពាណិជ្ជកម្មជាដើម។ ដែលបានធ្វើអ្នកប្រើប្រាស់របាយការណ៍ទាំងខាងក្នុងនិងខាងក្រៅមានភាពងាយស្រួលក្នុងការវិភាគដើម្បីធ្វើការសម្រាចចិត្តទៅផ្នែកហិរញ្ញវត្ថុ។ វាជាហេតុដែលនាំឱ្យមានការទាក់ទាញនូវអ្នកវិនិយោគទាំងក្នុងនឹងក្រៅប្រទេសមកធ្វើការវិនិយោគដែលធ្វើអោយសេដ្ឋកិច្ចមានការរីកចម្រើនជារើយៗ។ ទោះបីស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ២ បានផ្តល់នូវអត្ថប្រយោជន៍ច្រើនយ៉ាងណាក៏ដោយក៏នូវមានចំណុចខ្វះខាតមួយចំនួនតូចដែលធ្វើអោយមានផលប៉ះពាល់ខ្លាំងក្នុងការអនុវត្តនោះដែរ។ ដោយភាពបត់បែននៃវិធីសាស្ត្រគណនាថ្លៃដើមក្នុងស្តង់ដានេះអាចនាំឱ្យមាន ភាពខុសគ្នាក្នុងការរាយការណ៍ចំណេញ រវាងក្រុមហ៊ុនដែលប្រើវិធីសាស្ត្រផ្សេងគ្នា ជាពិសេសនៅពេលដែលតម្លៃទំនិញមានការប្រែប្រួលខ្លាំង ទោះបីយ៉ាងណាក៏ដោយផលប៉ះពាល់នេះវាមិនមានឥទ្ធិពលក្នុងការអនុវត្តនូវស្តងដានេះផងដែរ។

# មាតិកា


ទំព័រ

អារម្ភកថា ............................................................................................................ i

រចនាសម្ព័នក្រុម.................................................................................................... ii

សេចក្តីថ្លែងអំណរគុណ ........................................................................................... iii

អំណះអំណាង ......................................................................................................... iv

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ................................................................................ v

មាតិកា.................................................................................................................. vi


## ជំពូកទី១
## សេចក្តីផ្តើម


១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ...............................................................................១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ...............................................................................២

១.២.១ តើគោលការណ៍នៃការគ្រប់គ្រងសន្និធិរបស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ២ មានអ្វីខ្លះ? ..............................................................................................................២

១.២.២ តើស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ២ ផ្តល់គុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ?........២

១.៣ គោលបំណងនៃការស្រាវជ្រាវ.................................................................................២

១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ.......................................................២

១.៤.១ ទំហំដែនកំណត់...............................................................................................២

១.៤.២ វិសាលភាពនៃការស្រាវជ្រាវ...............................................................................២

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ.....................................................................................២

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ.................................................................................៣

១.៦.១ ចំពោះក្រុមអ្នកស្រាវជ្រាវផ្ទាល់..........................................................................៣

១.៦.២ ចំពោះស្ថាប័ន .................................................................................................៣

១.៦.៣ ចំពោះសង្គម....................................................................................................៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ...................................................................................៤


## ជំពូកទី២
## ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា


២.១ លក្ខណៈទូទៅនៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា............................................ ៥

២.១.១ និយមន័យស្តង់ដារ ......................................................................................... ៥

២.១.២ ប្រវត្តិនៃស្តង់ដារ ............................................................................................. ៦

២.១.៣ ទស្សនៈនៃស្តង់ដា ..... ៧
២.២ គោលការណ៍សំខាន់ៗរបស់ស្តង់ដាគណនេយ្យអន្តរជាតិ ..... ៧
២.២.១ និយមន័យគណនេយ្យនិង ស្តង់ដាគណនេយ្យ ..... ៨
២.២.២ ប្រវត្តិនៃគណនេយ្យនិង ស្តង់ដាគណនេយ្យ ..... ១០
២.២.៣ ទ្រឹស្តីនៃគណនេយ្យនិង ស្តង់ដាគណនេយ្យ ..... ១២
២.៣ ការទទួលស្គាល់សន្និធិជាទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុនៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ..... ១៤
២.៣.១ និយមន័យទ្រព្យសកម្ម និងរបាយការណ៍ហិរញ្ញវត្ថុ ..... ១៤
២.៣.២ ប្រវត្តិទ្រព្យសកម្ម និងរបាយការណ៍ហិរញ្ញវត្ថុ ..... ១៥
២.៣.៣ ទ្រឹស្តីនៃទ្រព្យសកម្ម ..... ១៦
២.៣.៤ សារៈសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ ..... ១៩

## ជំពូកទី៣

## សារៈសំខាន់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ២

៣.១ ស្ថានភាពទូទៅនៃនិយ័តករគណនេយ្យនិងសវនកម្ម ..... ២១
៣.១.១ ប្រវត្តិនៃនិយ័តករគណនេយ្យនិងសវនកម្ម ..... ២១
៣.១.២ បេសកកម្ម និងទស្សនវិស័យរបស់និយ័តករគណនេយ្យនិងសវនកម្ម ..... ២២
៣.១.៣ រចនាសម្ព័ន្ធនៃនិយ័តករគណនេយ្យនិងសវនកម្ម ..... ២២
៣.២ គោលការណ៍សំខាន់ៗនៃស្តង់គណនេយ្យអន្តរជាតិនៃកម្ពុជាលេខ២ ..... ២៣
៣.២.១ និយមន័យ ..... ២៣
៣.២.២ ការវាស់វែងថ្លៃដើមសន្និធិ ..... ២៣
៣.២.៣ វិធីសាស្ត្រការគណនាថ្លៃដើមសន្និធិ ..... ២៤
៣.២.៤ តម្លៃសុទ្ធគួរឱ្យទុកចិត្តបាន ..... ២៥
៣.២.៥ ការទទួលស្គាល់ជាចំណូល ..... ២៦
៣.២.៦ ការលាតត្រដាងពត៌មាន ..... ២៧
៣.៣ លក្ខខណ្ឌដែលសន្និធិគួរត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុ ..... ២៨

## ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ..... ២៩
៤.២ ការវិភាគលើចំណុចខ្សោយ ..... ៣០

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........................................................................................................ ៣១
៥.២ ការផ្តល់អនុសាសន៍ .......................................................................................................៣៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំដើមនៃការស្រាវជ្រាវ

នាពេលបច្ចុប្បន្ន នៅជុំវិញពិភពលោកមានការរីចម្រើន ដូចជាវិស័យសេដ្ឋកិច្ច បច្ចេកវិទ្យា ចំណេះដឹង និងទំនាក់ទំនងរវាងប្រទេសនឹងប្រទេស។ ទន្ទឹមនឹងការរីកចម្រើននៃសេដ្ឋកិច្ចពិភពលោក ប្រទេសនីមួយៗបានខិតខំប្រឹងប្រែងអភិវឌ្ឍន៍ខ្លួនឯងលើគ្រប់វិស័យ មានដូចជាវិស័យអប់រំ វិស័យទេសចរណ៍ វិស័យទូរគមនាគមន៍ វិស័យវាយនភ័ណ្ឌ វិស័យហិរញ្ញវត្ថុ ដែលក្នុងនោះក៏ឃើញថាវិស័យអប់រំបានរីកដុះដាលជាខ្លាំង ទៅលើគ្រប់ជំនាញមានដូចជាជំនាញគណនេយ្យ ជំនាញហិរញ្ញវត្ថុ ជំនាញគ្រប់គ្រង ជំនាញសេដ្ឋកិច្ច ដែលសុទ្ធតែជាជំនាញមួយដែលមាននិស្សិតសិក្សាច្រើនជាងគេនៅតាមសកលវិទ្យាល័យ ឬមហាវិទ្យាល័យ។ ដោយមានគោលនយោបាយប្រព័ន្ធទីផ្សារសេរី ដែលមានភាពចាំបាច់ទៅលើវិស័យគណនេយ្យ គឺមានសារៈសំខាន់ខ្លាំងក្នុងសេដ្ឋកិច្ចដែលកំពុងរីកលូតលាស់របស់កម្ពុជាត្រូវបានមើលឃើញជាក្បាលម៉ាស៊ីនដ៏សំខាន់ដើម្បីជំរុញសេដ្ឋកិច្ចអោយឆ្ពោះទៅមុខ និងជំរុញប្រទេសជាតិអភិវឌ្ឍន៍។ ដើម្បីសម្រេចបានសមិទ្ធផលនេះ ព្រះរាជាណាចក្រកម្ពុជាត្រូវការគណនេយ្យករជំនាញ និងអ្នកជំនាញហិរញ្ញវត្ថុ ក៏ដូចជាសវនករដែលមានជំនាញខ្ពស់ ដើម្បីធានាថាសហគមនធុរកិច្ចគោរពតាមបទដ្ឋាន និងបទប្បញ្ញត្តិអន្តរជាតិ។ អាជីពគណនេយ្យករសព្វថ្ងៃមានការពេញនិយម និងតម្រូវការខ្ពស់ ចំណេះដឹង ជំនាញដែលទទួលបានក្នុងការបណ្តុះបណ្តាល និងមានប្រយោជន៍ក្នុងជីវិតរបស់ប្រជាពលរដ្ឋគ្រប់រូបនៃប្រទេសកម្ពុជា។ សព្វថ្ងៃយើងសង្កេតឃើញថាគណនេយ្យ ក៏ជាព័ត៌មានដ៏សំខាន់ដែលប្រាប់នូវស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពនីមួយៗ។ មួយវិញការជ្រើសរើសថ្នាក់សិក្សានូវមហាវិទ្យាល័យជំនាញគណនេយ្យពិតជាសំខាន់ណាស់ដោយសារវាជួយអោយមនុស្សគ្រប់គ្នាយល់ដឹងពីគណនេយ្យ និងវិស័យជំនួញជាដើមដែលរួមផ្សំនូវឱកាសការងារជាច្រើនបន្ថែមទៀត។

នៅក្នុងប្រទេសកម្ពុជា ការអប់រំនូវជំនាញគណនេយ្យមានច្រើនសម្បូរបែប ដូចជាតាមមហាវិទ្យាល័យតាមវិទ្យាស្ថាន គឺសុទ្ធសឹងតែមាននូវការអប់រំនូវមុខជំនាញដោយផ្តោតទៅតាមស្តង់ដាគណនេយ្យអន្តរជាតិចំពោះនិស្សិតដែលជ្រើសរើសមកសិក្សាដើម្បីក្លាយជាគណនេយ្យករ ដែលមានទំនួលខុសត្រូវចម្បងនៃតំណែងមួយនេះ គឺការកត់ត្រាទិន្នន័យហិរញ្ញវត្ថុប្រចាំខែ និងប្រចាំឆ្នាំ។ ក្រៅពីនេះគណនេយ្យករមានភារកិច្ចរៀបចំឯកសារទៅកាន់អតិថិជន ឬអ្នកផ្គត់ផ្គង់ វិភាគប្រាក់ចំណេញ និងលំហូរចំណូលរួចបង្កើតផែនការកញ្ចប់ថវិការផងដែរ។ ទំនួលខុសត្រូវខាងលើនេះអាចផ្លាស់ប្តូរទៅតាមតួនាទីរបស់គណនេយ្យករ។

ដូច្នេះអង្គការ សហគ្រាស ស្ថាប័នជាតិ ស្ថាប័នអន្តរជាតិ និងអាជីវកម្មមួយចំនួន គឺសុទ្ធសឹងតែត្រូវការផ្នែកគណនេយ្យ ដើម្បីកត់ត្រាប្រតិបត្តិការ សរុបតួលេខ វិភាគទិន្នន័យចំណូល ចំណាយ និងសម្រាប់ធ្វើរបាយការណ៍ផ្សេងៗ ដែលពាក់ព័ន្ធនឹងស្ថាប័នរបស់ខ្លួន។ គណនេយ្យគឺជាគ្រឹះដ៏សំខាន់ និងចម្បងសម្រាប់សេដ្ឋកិច្ចជាតិ អន្តរជាតិ ស្ថាប័នរដ្ឋ និងស្ថាប័នឯកជនសម្រាប់ទ្រទ្រង់រាល់ប្រតិបត្តិការព្រមទាំងចាំជួយដោះស្រាយរាល់បញ្ហាគ្រប់ស្ថាប័នមិនអាចខ្វះបានដែលទាក់ទងនឹងហិរញ្ញវត្ថុ ដើម្បីអោយមានភាពងាយស្រួលស្វែងរកភាពរីកចម្រើន ឬអន់ថយរបស់សេដ្ឋកិច្ច និងស្ថាប័ននានា នាពេលបច្ចុប្បន្ន និងពេលអនាគត។ ដោយសារតែឃើញអត្ថប្រយោជន៍ និងសារៈសំខាន់បែបនេះហើយទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើស

ប្រធានបទស្តីពី «**សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២**» យកមកសិក្សាស្រាវជ្រាវ និងចងក្រងជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ស្តង់ដាគណនេយ្យមានសារៈសំខាន់ខ្លាំងសម្រាប់គណនេយ្យករ ដែលកំពុងបម្រើការយ៉ាងសកម្មក្នុងប្រទេសកម្ពុជាខណៈដែលវិស័យធុរៈកិច្ចរបស់ប្រទេសកម្ពុជា ត្រូវបានគេមើលឃើញថាវិស័យហិរញ្ញវត្ថុជាក្បាលម៉ាស៊ីនដ៏សំខាន់ដើម្បីជំរុញអោយសេដ្ឋកិច្ចឆ្ពោះទៅមុខ និងជំរុញប្រទេសជាតិអោយក្លាយជាប្រទេសអភិវឌ្ឍន៍។ អាស្រ័យហេតុដូច្នេះហើយបានជាយើងចាំបាច់ត្រូវការសិក្សាស្តង់ដាជំនាញគណនេយ្យ ដើម្បីជួយអភិវឌ្ឍន៍នូវធនធានសេដ្ឋកិច្ចដែលស្នូលសម្រាប់ប្រទេសកម្ពុជាអោយរីកចម្រើនជាលំដាប់។ ដើម្បីជាទុន និងជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងអំពីទិដ្ឋភាពទូទៅជុំវិញនៃប្រធានបទ **សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២** យើងគួរគប្បីស្វែងយល់អំពីពាក្យគន្លឹះ និងសំណួរមួយចំនួនខាងក្រោមនេះជាមុនសិន។

១. តើស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២ មានគោលការណ៍សំខាន់ៗអ្វីខ្លះ?

២. តើមានលក្ខខណ្ឌអ្វីខ្លះដែលសន្និធិគួរត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីស្វែងយល់អំពីសារៈសំខាន់នៃស្តង់ដានៃគណនេយ្យអន្តរជាតិនៃកម្ពុជា២ រួមមាន៖

- យល់ដឹងពីគោលការណ៍សំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២
- យល់ដឹងបន្ថែមពីសារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២
- យល់ដឹងពីការទទួលស្គាល់សន្និធិជាទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- យល់ដឹងការវាស់វែង និងការគណនាថ្លៃដើមនៃសន្និធិ
- យល់ដឹងពីការបង្ហាញ និងការលាតត្រដាងព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុ

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែលកំណត់

របាយការណ៍សិក្សាស្រាវជ្រាវនេះ ផ្តោតសំខាន់លើការសិក្សាអំពីសារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២ ក្តោបទៅលើគោលការណ៍ និងការទទួលស្គាល់ជាទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ដំណើរការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងក្នុងគោលដៅឆ្លុះបញ្ចាំងតថៈភាពអំពីសារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២ ដែលអនុម័តឱ្យប្រើប្រាស់ដោយនិយ័តករគណនេយ្យនិងសវនកម្មសម្រាប់ក្រុមហ៊ុនដែលមានកាតព្វកិច្ចបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុជាសាធារណៈ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីអោយដំណើរការនៃការសរសេរសារណាទៅលើប្រធានបទស្តីពី សារៈសំខាន់នៃស្តង់ដានៃគណនេយ្យអន្តរជាតិនៃកម្ពុជា២ អោយបានជោគជ័យក្រុមយើងខ្ញុំបានប្រើប្រាស់វិធីសាស្ត្រគុណវិស័យក្នុងការស្វែងរកទិន្នន័យ។

សម្រាប់សំណួរស្រាវជ្រាវទី១៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជា កម្រងឯកសារនានា វិធីសាស្ត្រតាមរយៈគេហទំព័រ ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗបានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា ការដកស្រង់នូវឯកសារមេរៀនទាំងឡាយណាដែលពាក់ព័ន្ធនឹងប្រធានបទ ការអានកម្រងឯកសារផ្សេងៗ របាយការណ៍ចាស់ៗដែលសិស្សច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅលោកគ្រូណែនាំបន្ថែម។

សម្រាប់សំណួរស្រាវជ្រាវទី២៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជា កម្រងឯកសារនានា វិធីសាស្ត្រតាមរយៈគេហទំព័រ ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗបានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា ការដកស្រង់នូវឯកសារមេរៀនទាំងឡាយណាដែលពាក់ព័ន្ធនឹងប្រធានបទ ការអានកម្រងឯកសារផ្សេងៗ របាយការណ៍ចាស់ៗដែលសិស្សច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅលោកគ្រូណែនាំបន្ថែម។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ គឺជាការនាំមកនូវការអភិវឌ្ឍន៍ផ្នែកចំណេះដឹង និងអត្ថប្រយោជន៍ជាច្រើន ជាពិសេសចំពោះ៖

### ១.៦.១ ចំពោះក្រុមអ្នកស្រាវជ្រាវផ្ទាល់

- យល់ដឹងពីគោលការណ៍សំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២
- យល់ដឹងពីការទទួលស្គាល់សន្និធិជាទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- យល់ដឹងការវាស់វែង និងការគណនាថ្លៃដើមនៃសន្និធិ
- យល់ដឹងពីការបង្ហាញ និងការលាតត្រដាងព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- យល់ដឹងកាន់តែច្បាស់អំពីសារៈសំខាន់នៃស្តង់ដានៃគណនេយ្យអន្តរជាតិនៃកម្ពុជា២
- ចេះធ្វើការងារជាក្រុម និងចេះសម្របសម្រួលដោះស្រាយបញ្ហាក្នុងក្រុម
- ពង្រឹងបន្ថែមលើទំនួលខុសត្រូវលើកិច្ចការស្រាវជ្រាវ

### ១.៦.២ ចំពោះស្ថាប័ន

- បានដឹងពីចំណុចខ្លាំង និងចំណុចខ្សោយដើម្បីយកមកកែលម្អ និងអភិវឌ្ឍន៍

### ១.៦.៣ ចំពោះសង្គម

- បានផ្សព្វផ្សាយពីចំណេះដឹងទៅដល់និស្សិតជំនាន់ក្រោយ
- ចងក្រងជាឯកសារសម្រាប់សិស្សប្អូនធ្វើការសិក្សាស្រាវជ្រាវបន្ត
- ផ្តល់បទពិសោធន៍ និងចំណេះដឹងបន្ថែម
- ចំណុចល្អៗ អាចទុកធ្វើជាបទពិសោធន៍សំរាប់និស្សិតជំនាន់ក្រោយ....។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះចំណុចរចនាសម្ព័ន្ធនៃការស្រាវជ្រាវ ធ្វើឡើងក្នុងគោលបំណងដើម្បីស្វែងយល់បន្ថែមទាក់ទងនឹងខ្លឹមសារ និងដំណាក់កាលបន្តបន្ទាប់ទៅតាមជំពូកនីមួយៗ ក្នុងនោះក្រុមយើងខ្ញុំបានរួមបញ្ចូល នូវសេចក្តីផ្តើម គោលបំណង សារៈសំខាន់នៃការស្រាវជ្រាវ ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយរបស់ស្តង់ដានៃ

គណនេយ្យអន្តរជាតិនៃកម្ពុជា២ សេចក្តីសន្និដ្ឋានក៏ដូចជាការផ្តល់អនុសាសន៍ល្អៗ ទៅលើការស្រាវជ្រាវ និងធ្វើការបែងចែកខ្លឹមសារសំខាន់ៗជាប្រាំជំពូកទៅតាមដំណាក់កាលនីមួយៗដូចខាងក្រោម៖

**ជំពូកទី១៖ (សេចក្តីផ្តើម)** និយាយសង្ខេបលំនាំបញ្ហា ចំណោទបញ្ហា មូលហេតុនិងហេតុផលនៃការបង្កើតឱ្យមានការស្រាវជ្រាវសារណានេះឡើង គោលបំណងនៃការស្រាវជ្រាវ ការកំណត់ពីទំហំដែនកំណត់ក្នុងការស្រាវជ្រាវ ការរិះរកនូវវិធីសាស្ត្រនៃការស្រាវជ្រាវរកទិន្នន័យ និងអត្ថន័យដែលបានកំណត់ក៏ដូចជាចោទជាសំណួរ ជាពិសេសស្វែងរកនូវសារៈសំខាន់នៃការសិក្សាស្រាវជ្រាវ និងចងក្រងទៅលើប្រធានបទក៏ដូចជាសារណាមួយនេះ។

**ជំពូកទី២៖ (ស្តង់ដាបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា)** បកស្រាយ ទៅលើនិយមន័យ ទ្រឹស្តីរបស់អ្នកប្រាជ្ញដែលពាក់ព័ន្ធ លក្ខណៈទូទៅក៏ដូចជាប្រវត្តិដែលពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវ។

**ជំពូកទី៣៖ (សារៈសំខាន់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២)** បរិយាយទៅលើស្ថានភាពទូទៅការវិវត្ត គោលការណ៍សំខាន់ៗនៃការគ្រប់គ្រងសិន្និធិ ការទទួលស្គាល់សន្និធិជាទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុនៃស្តង់គណនេយ្យអន្តរជាតិនៃកម្ពុជា២។

**ជំពូកទី៤៖ (ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ)** ធ្វើការវិភាគចំណុចខ្លាំង និងចំណុចខ្សោយនៃសំខាន់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២ ដើម្បីធ្វើការកែប្រែនូវចំណុចខ្សោយនោះ។

**ជំពូកទី៥៖ (សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍)** ក្រោយពីបានបកស្រាយអត្ថន័យក៏ដូចខ្លឹមសារសំខាន់ៗទៅតាមដំណាក់កាលនីមួយៗរួចមក ត្រូវធ្វើការសរុបសេចក្តីក៏ដូចជាសេចក្តីសន្និដ្ឋានឡើងវិញនូវខ្លឹមសារប្រធានបទខាងលើ និងផ្តល់អនុសាសន៍ទៅលើចំណុចខ្វះខាត់ ដើម្បីកែលម្អឡើងវិញឱ្យកាន់តែប្រសើរជាងមុន។

# ជំពូកទី២

# សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា

## ២.១ លក្ខណៈទូទៅនៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា

### ២.១.១ និយមន័យ

**ស្តង់ដា** គឺជាកម្ចីមកពីភាសាបារាំង Standard ដែល មានន័យថា និយាម ឬបទដ្ឋាន។ ឧទាហរណ៍ថា ការសិក្សានេះគ្មាន ស្តង់ដា។ វាមានន័យថា ការសិក្សានេះមិនស្របទៅតាមនិយាមឬក្បួនខ្នាតទូទៅនៃប្រទេសជាច្រើន។ អាចថា គុណភាពអន់ជាងគេ របៀបបង្រៀនមិនច្បាស់លាស់។ល។ ការដឹកនាំគ្មាន ស្តង់ដា មានន័យថា ការដឹកនាំដោយគ្មានគោរពតាមក្បួនខ្នាតអ្វីទាំងអស់ ឬអាចនិយាយបែបផ្សេងថា ដឹកនាំតាមរបៀបរញ៉េរញ៉ៃ ឬតាមបែបអារម្មណ៍[1]។

**ស្តង់ដា** ថ្នាក់ពាក្យជាចំណូលមិនមែនសារពើពន្ធ ហិរញ្ញវត្ថុសាធារណៈ និង គយមានន័យថាពាក្យសព្ទនោះមាននិយមន័យច្រើនដូចខាងក្រោម៖

១. ខ្នាតគំរូមួយ ដែលត្រូវបានកំណត់ដោយច្បាប់នេះ ដើម្បីកំណត់គុណភាពពូជដំណាំ។

២. ឯកសារដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀងគ្នា និងបានអនុម័តដោយស្ថាប័នមានសមត្ថកិច្ចដែលមានលក្ខណៈជាក្បួន ជាគោលការណ៍ណែនាំ ឬជាចរិតលក្ខណៈសម្រាប់សកម្មភាព ឬលទ្ធផលដើម្បីទុកសម្រាប់ប្រើប្រាស់ជារួមនិងជាបន្តបន្ទាប់ សំដៅជានាសម្រេចឱ្យបានដល់ចំណុចប្រសើរបំផុតនៃបរិបទមួយ។

៣. ឯកសារដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀងគ្នា និងបានទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច ហើយឯកសារនោះផ្តល់នូវក្បួន គោលការណ៍ណែនាំ ឬចរិតលក្ខណៈសម្រាប់សកម្មភាព ឬលទ្ធផលរបស់វាទុកសម្រាប់ប្រើប្រាស់ជារួមនិងប្រើប្រាស់ឡើងវិញ ដើម្បីជានាឱ្យបានដល់ចំណុចប្រសើរបំផុត នៃបរិបទមួយ។

៤. លក្ខណៈវិនិច្ឆ័យសម្រាប់វាស់វែង និងវាយតម្លៃប្រតិបត្តិការរបស់មុខងារសវនកម្មផ្ទៃក្នុង និងជាមូលដ្ឋានសម្រាប់អនុវត្តមុខងារនេះតាមលក្ខណៈវិជ្ជាជីវៈពិតប្រាកដ[2]។

### ២.១.២ ប្រវត្តិនៃស្តង់ដា

ប្រវត្តិសាស្ត្រនៃស្តង់ដាបានកើតទៅតាមបទដ្ឋានបច្ចេកទេស មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងប្រវត្តិសាស្ត្រមនុស្សជាតិ។ ប្រវត្តិសាស្ត្រស្តង់ដាត្រូវបានប្រើជាមធ្យោបាយសម្រាប់ប្រជាជាតិនានា ដើម្បីគ្រប់គ្រងលើប្រជាជន និងដែនដីរបស់ពួកគេ។ ការបង្រួបបង្រួមច្បាប់មូលដ្ឋាននៃសង្គមជាបទដ្ឋានបានជាមូលដ្ឋានសម្រាប់ប្រជាជាតិរួបរួម និងការបង្កើតទីផ្សារ។ ឧទាហរណ៍ ព្រះចៅអធិរាជទីមួយនៃប្រទេសចិន(កំឡុងពេលរាជវង្សឈិន) បានបង្រួបបង្រួមនគរបុរាណនៅពាសពេញទ្វីបចិន។ បន្ទាប់ពីបង្រួបបង្រួម ប្រព័ន្ធនៃទម្ងន់និងវិធានការត្រូវបានបង្រួបបង្រួមជាស្តង់ដាមួយក្នុងកំឡុងសម័យរាជវង្សឈិន។

ការរួបរួមនៃប្រព័ន្ធនេះត្រូវបានគេនិយាយថា បានបង្កើតមូលដ្ឋានគ្រឹះនៃចិនសម័យទំនើប។ នៅឆ្នាំទីម្ភៃប្រាំមួយនៃរជ្ជកាលរបស់ព្រះអង្គ អធិរាជទីមួយ បានបង្រួបបង្រួមតំបន់ចិនបុរាណនៅគ្រប់វេន ហើយព្រះ

---

[1] thmeythmey. (2016, December 24). *និយមន័យស្តង់ដា*. Retrieved from https://thmeythmey.com/detail/47825

[2] Videos Learning. (2023, February 15).*និយមន័យស្តង់ដា*. Retrieved from https://videoslearning.com/1-2887/

អម្ចាស់ និងប្រជាជនមានសន្តិភាពយ៉ាងខ្លាំង។ ព្រះអង្គមានព្រះនាមថាព្រះចៅអធិរាជ។ បន្ទាប់មក ព្រះអង្គបានចេញព្រះរាជក្រឹត្យមួយដល់នាយករដ្ឋមន្ត្រី ដើម្បីបង្រួបបង្រួមប្រព័ន្ធទម្ងន់ និងវិធានការនិងដើម្បីបញ្ជាក់អំពីបញ្ហាវាស់វែងដែលគួរឱ្យសង្ស័យ។ ម្យ៉ាងវិញទៀត នៅក្នុងយុគសម័យកណ្តាល នៅអឺរ៉ុប មិនមានស្តង់ដាបង្រួបបង្រួមសម្រាប់វាស់ប្រវែងរូបិយប័ណ្ណ ឬទម្ងន់ទេ។ ជាឧទាហរណ៍ នៅតំបន់ Baden នៃប្រទេសអាល្លឺម៉ង់ នាពេលបច្ចុប្បន្ននេះ មានវិធីសាស្ត្រ 122 នៃការវាស់វែងប្រវែងតែម្នាក់ឯង។ សម្រាប់ទម្ងន់មានវិធីសាស្ត្រ 80 នៃការវាស់វែងត្រូវបានប្រើប្រាស់យ៉ាងធូន់ធួរ។ ម្យ៉ាងវិញទៀត ស្តង់ដាឯកសណ្ឋានមិនត្រូវបានបង្កើតឡើងយ៉ាងល្អនៅក្នុងមជ្ឈិមសម័យអឺរ៉ុបទេ។ អវត្តមាននេះអាចជាមូលហេតុនៃការបែកបាក់ដែលមាននៅក្នុងទ្វីបអឺរ៉ុបបច្ចុប្បន្ន ដែលត្រូវបានបែងចែកប្រទេសជាច្រើន។ អវត្តមាននៃច្បាប់សង្គមបង្រួបបង្រួម នាំឱ្យមានបែកបាក់ទីផ្សារផងដែរ។ ទីផ្សារដែលបែកខ្ញែកនេះ បានរារាំងសកម្មភាពរបស់ពាណិជ្ជករ និងប៉ះពាល់អវិជ្ជមានដល់សកម្មភាពសេដ្ឋកិច្ច។ ជាប្រវត្តិសាស្ត្រ ការបង្កើត និងការកំណត់ស្តង់ដាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសកម្មភាពសេដ្ឋកិច្ច[3]។

**២.១.៣ ទស្សនៈនៃស្តង់ដា**

តាមទស្សនៈខ្លះរបស់អ្នកប្រើប្រាស់ដោយផ្ទាល់មានដូចជា៖

- តាមទស្សនៈរបស់វិនិយោគិន ស្តង់ដា គឺសំខាន់ ព្រោះវាអនុញ្ញាតឱ្យពួកគេធ្វើការសម្រេចចិត្ត ដែលមានព័ត៌មានអំពីកន្លែងដែលត្រូវវិនិយោគប្រាក់របស់ពួកគេ។ នៅពេលដែលរបាយការណ៍ហិរញ្ញវត្ថុមានលក្ខណៈជាស្តង់ដា វាកាន់តែងាយស្រួលក្នុងការកំណត់និន្នាការ និងលំនាំនៅក្នុងការអនុវត្តហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយ។ នេះអាចជួយវិនិយោគិនកំណត់ថា តើក្រុមហ៊ុនមានសុខភាពផ្នែកហិរញ្ញវត្ថុ និងថាតើវាជាឱកាសវិនិយោគដ៏ល្អ។
- តាមទស្សនៈនៃការគ្រប់គ្រងក្រុមហ៊ុន ស្តង់ដាជួយធានាថា ព័ត៌មានហិរញ្ញវត្ថុត្រូវបានរាយការណ៍យ៉ាងត្រឹមត្រូវ និងជាប់លាប់។ នេះមានសារៈសំខាន់ ព្រោះវាអាចប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនក្នុងចំណោមវិនិយោគិន ម្ចាស់បំណុល និងភាគីពាក់ព័ន្ធផ្សេងទៀត។ ការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុមិនត្រឹមត្រូវ អាចនាំឱ្យមានផលវិបាកផ្នែកច្បាប់ និងហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុន ក៏ដូចជាការបាត់បង់ការជឿទុកចិត្តពីភាគីពាក់ព័ន្ធ។

ខាងក្រោមនេះ គឺជាចំណុចគន្លឹះមួយចំនួនដែលយើងគួរពិចារណានៅពេលនិយាយអំពីសារៈសំខាន់នៃការកំណត់បទដ្ឋានក្នុងការប្រៀបធៀបរបាយការណ៍ហិរញ្ញវត្ថុ៖

១. ស្តង់ដាធានាបាននូវភាពស្របគ្នា៖ ដោយការបង្កើតនូវស្តង់ដាគណនេយ្យឯកសណ្ឋាន ព័ត៌មានហិរញ្ញវត្ថុអាចត្រូវបានរាយការណ៍តាមលក្ខណៈស្របគ្នា នៅទូទាំងក្រុមហ៊ុន និងឧស្សាហកម្មផ្សេងៗគ្នា។ នេះធ្វើឱ្យវាកាន់តែងាយស្រួលក្នុងការប្រៀបធៀបរបាយការណ៍ហិរញ្ញវត្ថុ និងកំណត់និន្នាការ និងគំរូ។

២. ស្តង់ដាធ្វើអោយប្រសើរឡើងនូវតម្លាភាព៖ នៅពេលដែលព័ត៌មានហិរញ្ញវត្ថុត្រូវបានរាយការណ៍តាមលក្ខណៈស្តង់ដាមួយ វាកាន់តែងាយស្រួលក្នុងការយល់ដឹង និងបកស្រាយ។ ការធ្វើបែបនេះ ធ្វើអោយមាន

[3] RIETI. TAMURA Suguru. (2021, April 19). *The Role and Historical Development of Standards.* Retrieved from https://www.rieti.go.jp/en/columns/a01_0641.html

ភាពប្រសើរឡើងនៃតម្លាភាព និងជួយអ្នកវិនិយោគធ្វើការសម្រេចចិត្តដែលមានព័ត៌មានអំពីកន្លែងដែលពួកគេត្រូវវិនិយោគប្រាក់របស់ពួកគេ។

៣. ស្តង់ដាធានាផ្តល់នូវកម្រិតនៃការកាត់បន្ថយកំហុស៖ ស្តង់ដាជួយកាត់បន្ថយនៃការបង្កើតកំហុសភាពមិនស៊ីសង្វាក់គ្នានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ នេះជាការសំខាន់ ព្រោះកំហុសអាចមានផលវិបាកធ្ងន់ធ្ងរសម្រាប់ក្រុមហ៊ុន អ្នកវិនិយោគ និងអ្នកពាក់ព័ន្ធផ្សេងទៀត។

៤. ស្តង់ដាលើកកម្ពស់គណនេយ្យភាព៖ ដោយតម្រូវឱ្យក្រុមហ៊ុនរាយការណ៍ព័ត៌មានរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងលក្ខណៈស្តង់ដាមួយ ស្តង់ដាគណនេយ្យលើកកម្ពស់គណនេយ្យភាព និងជួយធានាថាក្រុមហ៊ុនត្រូវបានប្រារព្ធឡើងទៅតាមស្តង់ដាមួយស្របគ្នា។ ស្តង់ដា គឺចាំបាច់សម្រាប់ការប្រៀបធៀបរបាយការណ៍ហិរញ្ញវត្ថុ។ បើគ្មានវាទេ ព័ត៌មានហិរញ្ញវត្ថុអាចពិបាកក្នុងការបកស្រាយ និងវិភាគ ហើយវិនិយោគិនអាចមិនមានព័ត៌មានដែលពួកគេត្រូវការ ដើម្បីធ្វើការសម្រេចចិត្តដែលមានព័ត៌មាន។ តាមរយៈការបង្កើតស្តង់ដាគណនេយ្យឯកសណ្ឋាន យើងអាចដោះស្រាយអំណាចនៃភាពស្ថិតស្ថេរនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងលើកកម្ពស់តម្លាភាព ភាពត្រឹមត្រូវ និងគណនេយ្យភាពកាន់តែច្រើន[4]។

## ២.២ គោលការណ៍សំខាន់ៗនៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា

### ២.២.១ និយមន័យ

**គណនេយ្យ** គឺជាដំណើរការនៃការកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុដែលទាក់ទងនឹងអាជីវកម្ម ឬអង្គការធំៗផ្សេងទៀត។ ដំណើរការគណនេយ្យរួមមានការសង្ខេប ការវិភាគ និងការរាយការណ៍ប្រតិបត្តិការទាំងនេះទៅកាន់ភ្នាក់ងារត្រួតពិនិត្យ និយតករ និងអង្គភាពប្រមូលពន្ធ។ របាយការណ៍ហិរញ្ញវត្ថុដែលប្រើក្នុងគណនេយ្យគឺជាការសង្ខេបនៃប្រតិបត្តិការហិរញ្ញវត្ថុក្នុងការិយបរិច្ឆេទ និងសង្ខេបប្រតិបត្តិការរបស់ក្រុមហ៊ុនទីតាំងហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់[5]។

**គណនេយ្យ** គឺជាសកម្មភាពនៃការរក្សាកំណត់ត្រាលម្អិតនៃចំនួនប្រាក់ដែលអាជីវកម្ម ឬបុគ្គលទទួលបាន និងចំណាយ[6]។

**ស្តង់ដាគណនេយ្យ** គឺជាស្តង់ដាអនុញ្ញាតសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងជាប្រភពចម្បងនៃគោលការណ៍គណនេយ្យ ដែលទទួលយកជាទូទៅ GAAP (Generally Accepted Accounting Principles)។ ស្តង់ដាគណនេយ្យបញ្ជាក់ពីរបៀបដែលប្រតិបត្តិការ និងព្រឹត្តិការណ៍ផ្សេងៗត្រូវបានទទួលស្គាល់ វាស់វែងបង្ហាញ និងបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ គោលបំណងរបស់ពួកគេ គឺផ្តល់ព័ត៌មានហិរញ្ញវត្ថុដល់អ្នកវិនិយោគ អ្នកឱ្យខ្ចី ម្ចាស់បំណុល អ្នករួមចំណែក និងអ្នកផ្សេងទៀត ដែលមានប្រយោជន៍ក្នុងការសម្រេចចិត្តអំពីការផ្តល់ធនធានដល់អង្គភាព[7]។

**ស្តង់ដាគណនេយ្យ** គឺជាគោលនយោបាយជាលាយលក្ខណ៍អក្សរ ដែលចេញដោយអង្គភាពគណនេយ្យជំនាញ ឬដោយរដ្ឋាភិបាល ឬស្ថាប័ននិយតកម្មផ្សេងទៀត ដែលគ្របដណ្តប់លើទិដ្ឋភាពនៃការ

---

[44] Foster Capital. *Importance of Standardization*. Retrieved May, 12 2025 from https://fastercapital.com/startup-topic/Importance-of-Standardization.html

[5] Investopedia. Jason Fernando. (Update 2025, October 05). *What Is Accounting*? Retrieved from https://www.investopedia.com/terms/a/accounting.asp

[6] Collins. *Definition of 'accounting'*. Retrieved May, 20 2025 from https://www.collinsdictionary.com/dictionary/english/accounting

[7] AcSB. *What are accounting standards?* Retrieved May, 20 2025 from https://www.frascanada.ca/en/acsb/about/what-are-accounting-standards#:~:text=Accounting%20standards%20are%20authoritative%20standards,and%20disclosed%20in%20financial%20statements

ទទួលស្គាល់ ការវាស់ស្ទង់ ការព្យាបាល ការបង្ហាញ និងការបង្ហាញពីប្រតិបត្តិការគណនេយ្យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ[8]។

**ស្តង់ដាគណនេយ្យ** គឺជាសំណុំនៃនីតិវិធី និងវិធានការ ដែលជូនដំណឹងអំពីរបៀបដែលអាជីវកម្មដំណើរការសកម្មភាពគណនេយ្យរបស់ពួកគេ។ ពួកគេមានការអនុវត្តល្អបំផុត សម្រាប់ការកត់ត្រា វាស់វែង និងបង្ហាញពីប្រតិបត្តិការហិរញ្ញវត្ថុ។ ពួកគេអនុវត្តចំពោះផ្នែកទាំងអស់នៃសកម្មភាពរបស់ក្រុមហ៊ុនមួយ រួមទាំង ចំណូល ការចំណាយ មិនមែនជាសាច់ប្រាក់ ទ្រព្យសម្បត្តិ បំណុល ទុន និងរបាយការណ៍។ គោលបំណងចម្បងនៃស្តង់ដាគណនេយ្យ គឺដើម្បីផ្តល់នូវព័ត៌មានហិរញ្ញវត្ថុត្រឹមត្រូវ ដែលធនាគារ ទីភ្នាក់ងាររដ្ឋាភិបាល និងអ្នកវិនិយោគអាចប្រើបាននៅពេលមានអន្តរកម្មជាមួយក្រុមហ៊ុនឯកជន[9]។

**២.២.២ ប្រវត្តិគណនេយ្យ និងស្តង់ដាគណនេយ្យ**

❖ **ប្រវត្តិគណនេយ្យ**

ប្រវត្តិសាស្ត្រនៃគណនេយ្យ អាចត្រូវបានគេរកឃើញចាប់តាំងពីរាប់ពាន់ឆ្នាំណាស់មកហើយ ដោយយោងនៃអរិយធម៌នៅ Mesopotamia ហើយត្រូវបានគេនិយាយថា អភិវឌ្ឍន៍ជាមួយនឹងការសរសេរ ការរាប់ និងប្រាក់។ ជនជាតិអេហ្ស៊ីប និងជនជាតិបាប៊ីឡូនដំបូង បានបង្កើតប្រព័ន្ធសវនកម្ម ខណៈដែលជនជាតិរ៉ូមបានប្រមូលព័ត៌មានហិរញ្ញវត្ថុលម្អិតរបស់ខ្លួន។ ក្នុងអំឡុងរាប់ពាន់ឆ្នាំដំបូង ជនជាតិអេស៊ីបបានប្រើក្បួនសរសេរគម្ពីរ ដើម្បីសរសេរសៀវភៅនូវច្បាប់នានា ដែលមានមូលដ្ឋានលើអ្វីដែលគម្ពីរហៅថាសៀវភៅ។ ដោយជនជាតិអ៊ីតាលី ដែលគេបានហៅគាត់ថា បិតានៃគណនេយ្យទំនើប គឺលោក Luca Pacioli ដែលនៅក្នុង 1494បានពិពណ៌នាជាលើកដំបូងប្រព័ន្ធនៃការចុះបញ្ជីជាគុទ្វេដងដែលត្រូវបានប្រើដោយពាណិជ្ជករ Venetian ដោយបានប្រើប្រាស់ Summa de Arithmetica, Geometria, Proportioni et Proportionalita (គឺជាសៀវភៅ គណិតវិទ្យាដ៏ទូលំទូលាយ និងជាឯកសារយោងដែលសរសេរដោយលោក Luca Pacioli)។ ខណៈពេលដែលគាត់មិនមែនជាអ្នកបង្កើតគណនេយ្យ ប៉ុន្តែលោក Paciolio គឺជាអ្នកដំបូងដែលពណ៌នាអំពីប្រព័ន្ធនៃឥណពន្ធ និងឥណទាននៅក្នុងសៀវភៅទិនានុប្បវត្តិនិងសៀវភៅកត់ត្រាដែលនៅតែជាមូលដ្ឋាននៃប្រព័ន្ធគណនេយ្យនាពេលបច្ចុប្បន្ននេះ។ ជាមួយនឹងការចាប់ផ្តើមនៃបដិវត្តន៍ឧស្សាហកម្មនៅឆ្នាំ1760មានការរីកសាយនៃក្រុមហ៊ុន និងតម្រូវការសម្រាប់ប្រព័ន្ធគណនេយ្យមានកម្រិតខ្ពស់បន្ថែមទៀត។ ការអភិវឌ្ឍនៃសាជីវកម្មក៏បានបង្កើតក្រុមវិនិយោគិនធំៗនិងរចនាសម្ព័ន្ធកម្មសិទ្ធិកាន់តែស្មុគស្មាញ ដែលទាមទារឱ្យប្រព័ន្ធគណនេយ្យធ្វើការសម្របខ្លួន។

ចំណែកប្រទេសស្កុតឡែនបានធ្វើទំនើបកម្មគណនេយ្យៈ ក្នុងការកើតឡើងវិជ្ជាជីវៈទំនើបក៏មានឫសគល់របស់វានៅក្នុងប្រទេសស្កុតឡេន នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ1800 វិទ្យាស្ថានគណនេយ្យករនៅទីក្រុង Glasgow បានដាក់លិខិតស្នើសុំព្រះរាជធម្មនុញ្ញទៅព្រះមហាក្សត្រិយានី Victoria ដូច្នេះ គណនេយ្យករអាចបែងចែកខ្លួនឯងចេញពីមេធាវី ពីព្រោះជាយូរយារណាស់មកហើយ គណនេយ្យករបានស្ថិតនៅក្នុងសមាគមនៃមេធាវីដែលនឹងផ្តល់គណនេយ្យបន្ថែមលើសេវាកម្មច្បាប់របស់ក្រុមហ៊ុន។ នៅឆ្នាំ1854 វិទ្យាស្ថានបានអនុម័ត

[8] Clear Tax. (2024, June 14). *Accounting Standards*. Retrieved form https://cleartax.in/s/accounting-standards

[9] Indeed. Indeed Editorial Team. (2025, March 04). *Guide to Accounting Standards: Definition, Types and Uses*. Retrieved form https://www.indeed.com/career-advice/career-development/accounting-standards?__cf_chl_tk=96UG6icnK6ScDnAP495oJMWT-fIhyzVRCorqiT_8ZxYU-1741788335-1.0.1.1-swLPTnDizjmRGjj9AcePVsTOueiZ26KpXvIpm_yJQ2Y

"chartered accountant " សម្រាប់សមាជិករបស់ខ្លួនដែលជាពាក្យមួយ និងការកំណត់ព្រំដែនដែលនៅតែ Glasgow បានដាក់ញត្តិស្នើសុំព្រះរាជធម្មនុញ្ញទៅព្រះមហាក្សត្រិយានី Victoria ដូច្នេះ គណនេយ្យករអាចបែងចែកខ្លួនឯងចេញពីមេធាវី ពីព្រោះជាយូរយារណាស់មកហើយ គណនេយ្យករបានស្ថិតនៅក្នុងសមាគមនៃមេធាវីដែលនឹងផ្តល់គណនេយ្យបន្ថែមលើសេវាកម្មច្បាប់របស់ក្រុមហ៊ុន។ នៅឆ្នាំ1854វិទ្យាស្ថានបានអនុម័ត "chartered accountant" សម្រាប់សមាជិករបស់ខ្លួនដែលជាពាក្យមួយ និងការកំណត់ព្រំដែនដែលនៅតែមានទម្ងន់ផ្លូវច្បាប់នៅទូទាំងពិភពលោកទល់សព្វថ្ងៃនេះ។ លិខិតនេះត្រូវបានចុះហត្ថលេខាដោយគណនេយ្យករជនជាតិស្កុតឡេនចំនួន៤៩នាក់ ហើយបានអះអាងថា វិជ្ជាជីវៈគណនេយ្យមានតាំងពីយូរយារណាស់មកហើយនៅក្នុងប្រទេសស្កុតឡែន ជាវិជ្ជាជីវៈដែលមានការគោរពដ៏អស្ចារ្យ ហើយថាអ្នកអនុវត្តមួយចំនួនតូចកំពុងកើនឡើងយ៉ាងឆាប់រហ័ស។ ញត្តិនេះបានគូសបញ្ជាក់បន្ថែមអំពីជំនាញផ្សេងៗ ដែលតម្រូវឱ្យធ្វើជាគណនេយ្យករជំនាញបន្ថែមពីលើជំនាញគណិតវិទ្យា គណនេយ្យករចាំបាច់ត្រូវស្គាល់ពីគោលការណ៍ច្បាប់ទូទៅ ដោយសារពួកគេត្រូវបានជួលជាញឹកញាប់ដោយតុលាការដើម្បីផ្តល់ភស្តុតាងលើបញ្ហាហិរញ្ញវត្ថុ។ បដិវត្តឧស្សាហកម្ម នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ1800 បដិវត្តន៍ឧស្សាហកម្មនៅចក្រភពអង់គ្លេសកំពុងដំណើរការយ៉ាងល្អហើយ ទីក្រុងឡុងដ៍គឺជាមជ្ឈមណ្ឌលហិរញ្ញវត្ថុរបស់ពិភពលោក។ ជាមួយនឹងការរីកចម្រើននៃក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត និងការផលិត និងដឹកជញ្ជូនទ្រង់ទ្រាយធំ តម្រូវការបានកើនឡើងសម្រាប់គណនេយ្យករដែលមានជំនាញបច្ចេកទេស ដែលមានសមត្ថភាពគ្រប់គ្រងពិភពប្រតិបត្តិការដ៏ស្មុគស្មាញ ដែលកំពុងកើនឡើងនៃប្រតិបត្តិការសកល។ សារៈសំខាន់កាន់តែខ្លាំងឡើងនៃគណនេយ្យករបានជួយឱ្យប្រែក្លាយគណនេយ្យទៅជាវិជ្ជាជីវៈមួយដំបូងគេនៅចក្រភពអង់គ្លេស និងបន្ទាប់មកនៅសហរដ្ឋអាមេរិក។ នៅក្នុងឆ្នាំ1904 មនុស្សប្រាំបីនាក់បានបង្កើតសមាគមគណនេយ្យករនៅទីក្រុងឡុងដ៍ ដើម្បីបើកវិជ្ជាជីវៈដល់ទស្សនិកជនកាន់តែទូលំទូលាយមានតាមរយៈសមាគមចាស់ៗរបស់ចក្រភពអង់គ្លេស។ បន្ទាប់ពីការផ្លាស់ប្តូរឈ្មោះជាច្រើន សមាគម London Association of Accountants បានអនុម័តឈ្មោះសមាគមអ្នកគណនេយ្យករដែលមានវិញ្ញាបនបត្រ ACCA (Association of Chartered Certified Accountants)ក្នុងឆ្នាំ1996។ ក្នុងនាមជាគណនេយ្យករក្រមសីលធម៌វិជ្ជាជីវៈ ពិតជាមានសារៈសំខាន់ចំពោះគណនេយ្យ។ សតវត្សទី21 បានឃើញសកម្មភាពគួរឱ្យសង្ស័យមួយចំនួនរបស់គណនេយ្យករដែលបង្កឱ្យមានរឿងអាស្រូវទ្រង់ទ្រាយធំ។ នេះជាឧទាហរណ៍ រឿងអាស្រូវ Enron ក្នុងឆ្នាំ2001បានធ្វើឱ្យមានការរង្គោះរង្គើឧស្សាហកម្មគណនេយ្យ Arthur Andersen ដែលជាក្រុមហ៊ុនគណនេយ្យដ៏ធំបំផុតមួយរបស់ពិភពលោកនៅពេលនោះ បានឈប់ធ្វើអាជីវកម្ម។ ជាបន្តបន្ទាប់ក្រោមច្បាប់ Sarbanes - Oxley ដែលបានណែនាំថ្មី គណនេយ្យករឥឡូវនេះប្រឈមមុខនឹងការរឹតបន្តឹងយ៉ាងតឹងរ៉ឹងលើការពាក់ព័ន្ធរបស់ពួកគេ។ ប៉ុន្តែជារឿងហួសចិត្តចាប់តាំងពី Enron និងវិបត្តិហិរញ្ញវត្ថុក្នុងឆ្នាំ2008 គណនេយ្យករបានមានតម្រូវការយ៉ាងខ្លាំង ដោយសារបទប្បញ្ញត្តិសាជីវកម្មបានកើនឡើង ហើយត្រូវការជំនាញបន្ថែមទៀតដើម្បីបំពេញតម្រូវការនៃរាយការណ៍[10]។

[10] ACCA. *The history of how humans invented accounting*. Retrieved May, 12 2025 from https://www.accaglobal.com/gb/en/study-with-acca/blog/how-humans-invented-accounting.html

❖ ប្រវត្តិ និងការវិវត្តន៍នៃស្តង់ដាគណនេយ្យ

ការវិវត្តន៍នៃស្តង់ដាគណនេយ្យអន្តរជាតិបានចាប់ផ្តើមនៅឆ្នាំ ១៩៦៦ ជាមួយនឹងការផ្តល់យោបល់ឱ្យបង្កើតក្រុមសិក្សាទូទាំងពិភពលោក។ នៅឆ្នាំបន្ទាប់ ក្រុមសិក្សាអន្តរជាតិរបស់គណនេយ្យករត្រូវបានបង្កើតឡើង ហើយវាបានចាប់ផ្តើមបោះពុម្ពឯកសារលើប្រធានបទគណនេយ្យផ្សេងៗ ដែលមួយចំនួនបានបង្កើតមូលដ្ឋានគ្រឹះសម្រាប់ស្តង់ដាគណនេយ្យដែលចូលជាធរមាននៅពេលក្រោយ។ នៅឆ្នាំ ១៩៧៣ គណៈកម្មាធិការស្តង់ដាគណនេយ្យអន្តរជាតិ (IASC) ត្រូវបានបង្កើតឡើងក្នុងគោលបំណងបង្កើតស្តង់ដាគណនេយ្យដែលនឹងត្រូវបានអនុវត្តជាអន្តរជាតិ។ IASC បានចេញនូវស្តង់ដារមួយចំនួនដែលហៅថាស្តង់ដាគណនេយ្យអន្តរជាតិ ដែលដាក់ឈ្មោះ និងលេខពី IAS 1 ដល់ IAS 41 (កសិកម្ម)។ នៅឆ្នាំ 2001 ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (IASB) ដែលបង្កើតឡើងក្រោមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) បានជំនួស IASC ។IASB បានប្រកាសថាខ្លួននឹងអនុវត្តតាមស្តង់ដាដែលបានចេញរួចហើយដោយ IASC ប៉ុន្តែបានបញ្ជាក់ថាស្តង់ ដារថ្មីណាមួយនឹងត្រូវបានគេស្គាល់ថាជាផ្នែកមួយនៃស៊េរីដែលហៅថាស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិដែលវិវត្តដោយមូលនិធិ IFRS ។

គោលបំណងនៃ IFRS គឺដើម្បីអភិវឌ្ឍជាប្រយោជន៍សាធារណៈ ដែលជាសំណុំដែលមានគុណភាពខ្ពស់នៃស្តង់ដាគណនេយ្យដែលអាចយល់បាន ទទួលយកជាអន្តរជាតិ និងអាចអនុវត្តបាន។ មូលនិធិ IFRS ដែលជាអង្គការឯករាជ្យ មិនស្វែងរកប្រាក់ចំណេញ រៃអង្គាសថវិកាពីធនាគារ និងអង្គការផ្សេងទៀតដែលចង់ឱ្យមានស្តង់ដាគណនេយ្យអន្តរជាតិនៅគ្រប់ប្រទេសទាំងអស់។ IASB មានសមាជិកក្រុមប្រឹក្សាភិបាលដែលជាអ្នកជំនាញគណនេយ្យមកពីជុំវិញពិភពលោក ដែលមានជំនាញច្បាស់លាស់ក្នុងការកំណត់ស្តង់ដា និងការងារសិក្សា។

ស្តង់ដាគណនេយ្យបានឆ្លងកាត់ការផ្លាស់ប្តូរយ៉ាងសំខាន់ក្នុងប្រវត្តិសាស្ត្រ ដែលឆ្លុះបញ្ចាំងពីតម្រូវ ការវិវត្តនៃអាជីវកម្ម និងសេដ្ឋកិច្ច។ ចាប់ពីការបង្កើតគោលការណ៍គ្រឹះរហូតដល់ការណែនាំជាអន្តរជាតិ ដំណើរនៃស្តង់ដាគណនេយ្យបង្ហាញពីការសម្របខ្លួន និងភាពពាក់ព័ន្ធនៃវិន័យនៅក្នុងទិដ្ឋភាពហិរញ្ញវត្ថុដែលកាន់តែស្មុគស្មាញ។ នៅក្នុងអត្ថបទនេះ យើងនឹងស្វែងយល់ពីបរិបទប្រវត្តិសាស្ត្រនៃស្តង់ដាគណនេយ្យ ផល ប៉ះពាល់នៃបច្ចេកវិទ្យា និងនិន្នាការនាពេលអនាគតដែលបង្កើតការអនុវត្តគណនេយ្យហិរញ្ញវត្ថុ។

បរិបទប្រវត្តិសាស្ត្រនៃស្តង់ដាគណនេយ្យ ការវិវត្តន៍នៃស្តង់ដាគណនេយ្យត្រូវបានបង្កប់យ៉ាងជ្រៅនៅក្នុងប្រវត្តិសាស្ត្រនៃប្រតិបត្តិការសេដ្ឋកិច្ច និងភាពចាំបាច់សម្រាប់តម្លាភាពក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ដំបូងឡើយ គណនេយ្យបានវិវត្តដោយគ្មានច្បាប់ផ្លូវការ ដែលនាំឱ្យមានភាពមិនស្របគ្នាយ៉ាងសំខាន់ក្នុងរបាយការណ៍ហិរញ្ញវត្ថុនៅទូទាំងអាជីវកម្ម។ នៅពេលដែលពាណិជ្ជកម្មបានពង្រីក តម្រូវការសម្រាប់វិធីសាស្ត្រស្តង់ដាកាន់តែច្បាស់លាស់ ដែលជំរុញឱ្យមានការអភិវឌ្ឍន៍គោលការណ៍គណនេយ្យដែលទទួលយកជាទូទៅ (GAAP)។ គោលការណ៍ទាំងនេះបានបង្កើតឡើងដើម្បីបង្កើតក្របខ័ណ្ឌរួមដែលផ្តល់នូវរចនាសម្ព័ន្ធ និងការប្រៀបធៀប ដូច្នេះការបង្កើនទំនុកចិត្តក្នុងចំណោមវិនិយោគិន និងអ្នកពាក់ព័ន្ធក្នុងសុខភាពហិរញ្ញវត្ថុដែលបានវាយតម្លៃ។ប៉ុន្មានឆ្នាំមកនេះ ស្តង់ដាគណនេយ្យផ្សេងៗបានសម្របខ្លួនក្នុងការឆ្លើយតបទៅនឹងការផ្លាស់ប្តូរលក្ខខណ្ឌសេដ្ឋកិច្ច និងតម្រូវការបទប្បញ្ញត្តិ។ នៅសហរដ្ឋអាមេរិក ក្រុមប្រឹក្សាស្តង់ដាគណនេយ្យហិរញ្ញវត្ថុ (FASB) ត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យការអភិវឌ្ឍន៍ GAAP ដោយធានាថារបាយការណ៍ហិរញ្ញវត្ថុនៅ

តែមានជាប់ទាក់ទង និងមានប្រយោជន៍សម្រាប់ការសម្រេចចិត្ត។ ទន្ទឹមនឹងនេះ ចលនាអន្តរជាតិឆ្ពោះទៅរកការបញ្ចូលគ្នាជាមួយស្តង់ដាផ្សេងទៀត ជាពិសេសស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) មានគោលបំណងបង្រួបបង្រួមការអនុវត្តគណនេយ្យជាសកល។ ការផ្លាស់ប្តូរនេះគូសបញ្ជាក់ពីការទទួលស្គាល់ថា អាជីវកម្មជារឿយៗដំណើរការឆ្លងព្រំដែន និងទាមទារឱ្យមានក្របខ័ណ្ឌរាយការណ៍ដែលមានភាពសុខដុមរមនា ដើម្បីជួយសម្រួលដល់ពាណិជ្ជកម្ម និងការវិនិយោគអន្តរជាតិ។

ការវិវត្តន៍ជាបន្តបន្ទាប់នៃស្តង់ដាគណនេយ្យឆ្លុះបញ្ចាំងពីការអភិវឌ្ឍន៍សេដ្ឋកិច្ចកាន់តែទូលំទូលាយ វឌ្ឍនភាពបច្ចេកវិទ្យា និងការផ្លាស់ប្តូរទិដ្ឋភាពនៃបទប្បញ្ញត្តិហិរញ្ញវត្ថុ។ នៅពេលដែលឧស្សាហកម្មផ្លាស់ប្តូរ ហើយទម្រង់ថ្មីនៃប្រតិបត្តិការបានលេចឡើង ដូចជារូបិយប័ណ្ណឌីជីថល ឬឧបករណ៍ហិរញ្ញវត្ថុដ៏ស្មុគស្មាញ ស្តង់ដាគណនេយ្យក៏ត្រូវតែវិវឌ្ឍដែរ។ នេះធានាថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញយ៉ាងត្រឹមត្រូវអំពីការពិតសេដ្ឋកិច្ចរបស់អង្គការ ដោយផ្តល់ឱ្យភាគីពាក់ព័ន្ធនូវមូលដ្ឋានដែលអាចទុកចិត្តបានសម្រាប់ការវិនិច្ឆ័យ។ សព្វថ្ងៃនេះ បញ្ហាប្រឈមមិនគ្រាន់តែក្នុងការសម្របតាមស្តង់ដាទាំងនេះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានាឱ្យភាគីពាក់ព័ន្ធទាំងអស់ គណនេយ្យករ សវនករ និងអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ យល់ និងប្រកាន់ខ្ជាប់នូវគោលការណ៍ដែលមានចែងក្នុងក្របខ័ណ្ឌបែបនេះ។

❖ **ការយល់ដឹងអំពីគោលការណ៍គណនេយ្យដែលទទួលយកជាទូទៅ (GAAP)**

គោលការណ៍គណនេយ្យដែលទទួលយកជាទូទៅ (GAAP) ផ្តល់នូវក្របខ័ណ្ឌនៃស្តង់ដាគណនេយ្យដែលធានានូវភាពស៊ីសង្វាក់គ្នា ការប្រៀបធៀប និងភាពជឿជាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ គោលការណ៍ទាំងនេះមានសារៈសំខាន់សម្រាប់ក្រុមហ៊ុនសាធារណៈ ដោយសារពួកគេតម្រូវឱ្យប្រកាន់ខ្ជាប់នូវ GAAP នៅពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ពួកគេ។ សូម្បីតែក្រុមហ៊ុនឯកជនដែលស្វែងរកប្រាក់កម្ចី ឬការវិនិយោគត្រូវតែបង្ហាញព័ត៌មានហិរញ្ញវត្ថុរបស់ពួកគេក្នុងលក្ខណៈដែលអនុលោមតាម GAAP ដោយហេតុនេះការកសាងទំនុកចិត្តក្នុងចំណោមភាគីពាក់ព័ន្ធដោយផ្តល់នូវទិដ្ឋភាពប្រកបដោយតម្លាភាពអំពីសុខភាពហិរញ្ញវត្ថុរបស់ពួកគេ។ GAAP រួមបញ្ចូលនូវគោលគំនិតសំខាន់ៗដូចជា គណនេយ្យបង្គរ គោលការណ៍ផ្គូផ្គង និងការអភិរក្សនិយម ដែលរួមគ្នាបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការឆ្លុះបញ្ចាំងត្រឹមត្រូវនៃប្រាក់ចំណេញរបស់ក្រុមហ៊ុន។ ជាឧទាហរណ៍ គោលការណ៍ផ្គូផ្គងតម្រូវឱ្យប្រាក់ចំណូលត្រូវបានទទួលស្គាល់ក្នុងរយៈពេលដូចគ្នាជាមួយនឹងការចំណាយដែលកើតឡើងដើម្បីបង្កើតពួកគេ។ ការតម្រឹមនៃប្រាក់ចំណូល និងការចំណាយនេះអនុញ្ញាតឱ្យភាគីពាក់ព័ន្ធធ្វើការសម្រេចចិត្តដែលមានព័ត៌មានកាន់តែប្រសើរឡើងដោយផ្អែកលើប្រតិបត្តិការហិរញ្ញវត្ថុរបស់អង្គការ ជាជាងការបំភាន់ដោយតួលេខបង្ខូចទ្រង់ទ្រាយដែលបណ្តាលមកពីការអនុវត្តគណនេយ្យមិនស៊ីសង្វាក់គ្នា[11]។

### ២.២.៣ ទ្រឹស្តីនៃគណនេយ្យ និងស្តង់ដាគណនេយ្យ

❖ **ទ្រឹស្តីនៃគណនេយ្យ**

ទ្រឹស្តីគណនេយ្យគឺជាសំណុំនៃគំនិត និងគំនិតដែលណែនាំការអភិវឌ្ឍន៍ និងការអនុវត្តគណនេយ្យហិរញ្ញវត្ថុ វាជួយពន្យល់ពីរបៀបដែលគណនេយ្យហិរញ្ញវត្ថុត្រូវបានប្រើដើម្បីបង្កើតរបាយការណ៍ហិរញ្ញវត្ថុនិង

[11] Commerce Mates. (2019, October 15). *Importance of Accounting Standards*. Retrieved from https://commercemates.com/meaning-importance-of-accounting-standards/#google_vignette

របៀបដែលរបាយការណ៍ទាំងនោះត្រូវបានប្រើដើម្បីធ្វើការសម្រេចចិត្តអំពីការបែងចែកធនធាន។ ទ្រឹស្តីគណនេយ្យបានវិវត្តន៍ដើម្បីរួមបញ្ចូលនូវគំនិត និងគំនិតជាច្រើន រួមទាំងតួនាទីនៃគណនេយ្យក្នុងសង្គម ការប្រើប្រាស់ព័ត៌មានគណនេយ្យក្នុងការសម្រេចចិត្ត និងផលប៉ះពាល់នៃបច្ចេកវិទ្យាទំនើបលើការអនុវត្តគណនេយ្យ។

➢ ចំណុចសំខាន់ៗនៃគណនេយ្យ

-ទ្រឹស្តីគណនេយ្យទូទៅគឺ ៖ គណនេយ្យមូលដ្ឋាន បង្គរគោលការណ៍ផ្គូរផ្គង គោលការណ៍ទទួលស្គាល់ចំណូល និងគោលការណ៍បង្ហាញព័ត៌មានពេញលេញ

-ទ្រឹស្តីគណនេយ្យនីមួយៗមានគោលការណ៍ណែនាំ និងឧទាហរណ៍ខុសៗគ្នា អំពីរបៀបដែលអាជីវកម្មគួរកត់ត្រា និងរាយការណ៍ព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន

-ទ្រឹស្តីគណនេយ្យកំពុងផ្លាស់ប្តូរ និងធ្វើបច្ចុប្បន្នភាពឥតឈប់ឈរ ដើម្បីឱ្យសមនឹងតម្រូវការរបស់ក្រុមហ៊ុន និងអង្គការដែលប្រើប្រាស់វា។

➢ គោលបំណងនៃទ្រឹស្តីគណនេយ្យ៖ វត្ថុបំណងនៃទ្រឹស្តីគណនេយ្យ គេអាចចាត់ជា៤ក្រុម៖

១. ដើម្បីពន្យល់ពីលក្ខណៈ និងគោលបំណងនៃគណនេយ្យកម្ម

២. ដើម្បីពិពណ៌នាអំពីគោលគំនិត និងគោលការណ៍គណនេយ្យជាមូលដ្ឋាន

៣. ដើម្បីបង្កើតក្របខ័ណ្ឌសម្រាប់របាយការណ៍ហិរញ្ញវត្ថុ

៤. ដើម្បីដឹកនាំការអនុវត្តគោលការណ៍គណនេយ្យ[12]។

❖ **ទ្រឹស្តីនៃស្តង់ដាគណនេយ្យ**

ទាំងក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (IASB) និងក្រុមប្រឹក្សាស្តង់ដាគណនេយ្យហិរញ្ញវត្ថុ ( FASB) គឺ ប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍន៍ផ្អែកលើគោលការណ៍ស្តង់ដាគណនេយ្យ (IASB 2008: para. P 4;Bullen Crook 2005:1) សំខាន់មួយ។ សំណួរគឺថាតើមូលដ្ឋានគោលការណ៍នៃគណនេយ្យមានគ្រប់គ្រាន់ដែលបានបង្កើតឡើងដើម្បីបង្កើតគណនេយ្យសមស្របទៅនឹងស្តង់ដាមួយ។ សំណួរដែលបានចោទសួរទៀតថា តើគោលការណ៍នៃគណនេយ្យត្រូវបានអភិវឌ្ឍន៍គ្រប់គ្រាន់នៅក្នុងទ្រឹស្តីគណនេយ្យដែរឬទេ ?

ដោយបើយោងតាមលោក Wolk. Dodd និង Rozycki ទ្រឹស្តីជាធម្មតាត្រូវបានអភិវឌ្ឍន៍ និង ត្រូវបានចម្រាញ់តាមរយៈដំណើរការនៃការស្រាវជ្រាវ។ ដូច្នេះ សំណួរសមស្របមួយនឹងត្រូវបានពិចារណាថាតើគោលការណ៍របស់គណនេយ្យត្រូវបានអភិវឌ្ឍន៍គ្រប់គ្រាន់ និង ចម្រាញ់ក្នុងដំណើរការនៃការស្រាវជ្រាវដែរឬទេ។ ទោះជាយ៉ាងណាគួរទទួលស្គាល់ថា គោលការណ៍គណនេយ្យមិនមែនត្រូវបានបង្កើតឡើងតែម្នាក់ឯងតាមរយៈនៃការស្រាវជ្រាវនោះទេ។ ការស្រាវជ្រាវគណនេយ្យជាការអនុវត្តតាមរយៈដំណើរការកំណត់ស្តង់ដាបច្ចុប្បន្ន គឺជាកត្តាជំរុញដ៏សំខាន់នៃការអភិវឌ្ឍន៍គោលការណ៍នៃគណនេយ្យ។ តួនាទីនៃការស្រាវជ្រាវគណនេយ្យក្នុងការបង្កើតគោលការណ៍គណនេយ្យ និងការជូនដំណឹងអំពីដំណើរការរបស់អ្នកកំណត់ស្តង់ដា គឺជាសំណួរសិក្សាដ៏សំខាន់។ ភាពលំបាកក្នុងការស្រាវជ្រាវគណនេយ្យគឺថា បច្ចុប្បន្នមិនមានភាពទូលំទូលាយទេ។ ការពិតត្រូវបានកំណត់អត្តសញ្ញាណដោយជនជាតិអាមេរិកសមាគមគណនេយ្យករនៅឆ្នាំ1973។ Watts and Zimmer - Mann (1979:301) យល់ស្របថា មិនមានទ្រឹស្តីគណនេយ្យដែលទទួលយកជាទូទៅ ដើម្បីបង្ហាញ

[12] Khatabook. *What Is Accounting Theory in Financial Reporting?* Retrieved May, 20 2025 from https://khatabook.com/blog/basic-accounting-theories/

ពីភាពត្រឹមត្រូវនៃស្តង់ដាគណនេយ្យទេ ហើយអះអាងថា វានឹងមិនអាចសម្រេចបានឡើយ។ Riahi - Belkaoui (2004:108) បញ្ជាក់ថា គ្មានទ្រឹស្តីដ៏ទូលំទូលាយនៃគណនេយ្យត្រូវបានបង្កើតឡើង ហើយទ្រឹស្តីផ្សេងគ្នាកើតឡើងពីការប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នាក្នុងការកសាងទ្រឹស្តីគណនេយ្យ។ ដោយសារមិនទាន់មានទ្រឹស្តីគ្រប់ជ្រុងជ្រោយនៃគណនេយ្យត្រូវបានបង្កើតឡើង មានមួយសំណួរលើកឡើងថាអ្វីដែលជាមូលដ្ឋានទ្រឹស្តីដែលជាគោលការណ៍នៃគណនេយ្យ។ នេះជាសំណួរដ៏ពិបាកមួយដែលមានផ្នែកផ្សេងគ្នា។ គោលបំណងនៃអត្ថបទនេះ គឺដើម្បីរួមចំណែកដល់ការពិភាក្សានេះ ដោយពិចារណាលើតួនាទីសក្តានុពល ដែលប្រភេទផ្សេងគ្នានៃទ្រឹស្តីគណនេយ្យ និងការស្រាវជ្រាវ ដើរតួក្នុងការអភិវឌ្ឍន៍គោលការណ៍គណនេយ្យជាប់លាប់។ បញ្ហាគឺថាតើទ្រឹស្តីគណនេយ្យ និងការស្រាវជ្រាវពិតជារួមចំណែកដល់គោលការណ៍គណនេយ្យដែលបង្កើតឡើងដោយអ្នកកំណត់ស្តង់ដាឬអត់។ ដោយមានទ្រឹស្តីទាក់ទងទៅនឹងស្តង់ដាគណនេយ្យមានដូចជា៖ សាលាទីមួយ ផ្តោតលើការបង្កើតគោលការណ៍ និងពិពណ៌នាអំពីទ្រឹស្តីគណនេយ្យដូចខាងក្រោម ៖

1) ផ្តល់នូវស៊ុមទូទៅនៃឯកសារយោងដែលការអនុវត្តគណនេយ្យអាចត្រូវបានវាយតម្លៃនិង
2) ណែនាំការអភិវឌ្ឍន៍នៃការអនុវត្ត និងនីតិវិធីថ្មី (Hendriksen 1982:1) ដូច្នេះទ្រឹស្តីគណនេយ្យអាចត្រូវបានកំណត់ថាជាហេតុផលឡូជីខលក្នុងទម្រង់នៃសំណុំនៃគោលការណ៍ទូលំទូលាយ។

**ទ្រឹស្តីគណនេយ្យ** គឺជាការសន្មត់មូលដ្ឋាន និយមន័យ គោលការណ៍ និងគំនិតនានា ដែលស្ថិតនៅក្រោមច្បាប់គណនេយ្យ Making (Wolk et al.2008:2)។ សាលាផ្សេងទៀតនៃការពន្យល់នៃទ្រឹស្តីគណនេយ្យជាសកម្មភាពពន្យល់និងទស្សន៍ទាយថា៖ គោលបំណងចម្បងនៃទ្រឹស្តីគណនេយ្យ គឺដើម្បីផ្តល់នូវមូលដ្ឋានសម្រាប់ការទស្សន៍ទាយ និងការពន្យល់នៃឥរិយាបថគណនេយ្យ ព្រឹត្តិការណ៍ ដើម្បីពន្យល់ និងទស្សន៍ទាយការអនុវត្តគណនេយ្យ Watts Zimmerman 1986:2។

សាលាទី២ ព្យាយាមវាយតម្លៃការអនុវត្តដោយខ្លួនឯង Hendriksen (1982:1) បង្ហាញពីចំណូលចិត្តសម្រាប់សាលាដំបូងដូចខាងក្រោម ៖ ទ្រឹស្តីគណនេយ្យអាចត្រូវបានប្រើដើម្បីពន្យល់អំពីអនុវត្តន៍ដែលមានស្រាប់ដើម្បីទទួលបានការយល់ដឹងល្អប្រសើរអំពីពួកវា។ ប៉ុន្តែគោលបំណងសំខាន់បំផុតនៃទ្រឹស្តីគណនេយ្យគួរត្រូវបានផ្តល់ជូននូវសំណុំគោលការណ៍ដែលមានភាពស្របគ្នា ដែលបង្កើតជាស៊ុមទូទៅសម្រាប់ការប៉ាន់ប្រមាណ និងការអភិវឌ្ឍន៍នៃអនុវត្តន៍គណនេយ្យដែលមានសុវត្ថិភាព។ សាលាទាំងពីរនៃទ្រឹស្តីគណនេយ្យទាំងនេះ ត្រូវបានផ្អែកលើវិធីសាស្ត្រសំខាន់ពីរសម្រាប់ការអភិវឌ្ឍន៍ទ្រឹស្តីទូទៅ នោះគឺទាញយកដោយ UNIVERSITY នៃ JOHANNESBURG នៅ 22:12 ថ្ងៃទី 24 ខែកុម្ភៈឆ្នាំ 2016 (PT) លក្ខណៈនៃគណនេយ្យទ្រឹស្តី និងសការអភិវឌ្ឍន៍ទ្រឹស្តី សំណួរទ្រឹស្តីដែលមានស្រាប់ដើម្បីពិពណ៌នាអំពីទ្រឹស្តីគួរជាអ្វី ខណៈពេលដែលវិធីសាស្ត្រពិពណ៌នាស៊ើបអង្កេតបាតុភូត ដើម្បីពិពណ៌នាថាតើវាជាអ្វី (Hendriksen 1982; Riahi - Belkaoui 2004)[13] ។

## ២.៣ លក្ខខណ្ឌនៃការទទួលស្គាល់សន្និធិជាទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុ

### ២.៣.១ និយមន័យ

[13] ResearchGate. (2010, April 18). *The Role of Accounting Theory in the Development of Accounting Principles.* Retrieved from https://www.researchgate.net/publication/227429961_The_Role_of_Accounting_Theory_in_the_Development_of_Accounting_Principles

**ទ្រព្យសកម្ម** គឺជាទ្រព្យដែលត្រូវបានប្រើដោយអាជីវកម្មនៅក្នុងប្រតិបត្តិការប្រចាំថ្ងៃ ឬប្រចាំថ្ងៃរបស់ខ្លួន។ ទ្រព្យសកម្មអាចមានលក្ខណៈជាក់ស្តែងដូចជាអគារឬគ្រឿងបរិក្ខាឬរូបអរូបីដូចជាប៉ាតង់ឬសិទ្ធិអ្នកនិពន្ធ។ ទ្រព្យសកម្ម ត្រូវបានរាយជាទ្រព្យនៅលើតារាងតុល្យការរបស់អាជីវកម្ម។ ប្រភេទដែលជាចំណុចសំខាន់នៃភាពខុសគ្នានៃទ្រព្យសម្បត្តិគឺជាសមត្ថភាពបង្កើតប្រាក់ចំណូល។ ទ្រព្យសកម្មដែលតម្រូវឱ្យរក្សាប្រតិបត្តិការស្តង់ដាខណៈដែលប្រាក់ចំណូលត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្ម[14]។

**ទ្រព្យសកម្ម** មានន័យថា ប្រាក់ និងអ្វីៗផ្សេងទៀតដែលជាកម្មសិទ្ធិរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ហើយដែលអាចទូទាត់បំណុល ប្រើប្រាស់ ទទួលអត្ថប្រយោជន៍ និងបង្កើនប្រាក់ចំណូលបាន[15]។

**ទ្រព្យសកម្ម** គឺជាធនធានរូបី ឬអរូបី ដែលមានតម្លៃជារូបិយវត្ថុ ដែលអាចទាញយកនូវផលប្រយោជន៍ទៅអោយម្ចាស់នៃទ្រព្យ។ ទ្រព្យសកម្មអាចបង្កើតប្រាក់ចំណូល ដូចជាថ្លៃជួល ឬអាចបង្កើតប្រាក់ចំណេញប្រសិនបើលក់ ដូចជាភាគហ៊ុន ឬគ្រឿងអលង្ការ[16]។

**របាយការណ៍ហិរញ្ញវត្ថុ** គឺជាដំណើរការដ៏សំខាន់មួយសម្រាប់ក្រុមហ៊ុន និងអ្នកវិនិយោគិនព្រោះវាផ្តល់ព័ត៌មានសំខាន់ៗដែលបង្ហាញពីដំណើរការហិរញ្ញវត្ថុតាមពេលវេលា។ ស្ថាប័ននិយតកម្មរបស់រដ្ឋាភិបាល និងឯកជនក៏ត្រួតពិនិត្យទៅលើរបាយការណ៍ហិរញ្ញវត្ថុផងដែរ ដើម្បីធានាបាននូវសកម្មភាពពាណិជ្ជកម្ម សំណង និងហិរញ្ញវត្ថុដោយស្មើភាពគ្នា[17]។

**របាយការណ៍ហិរញ្ញវត្ថុ** គឺជាកំណត់ត្រាផ្លូវការនៃសកម្មភាពហិរញ្ញវត្ថុ និងទីតាំងរបស់អាជីវកម្ម បុគ្គល ឬអង្គភាពផ្សេងទៀត[18]។

**របាយការណ៍ហិរញ្ញវត្ថុ** គឺជាដំណើរការនៃការបង្កើតរបាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ស្ថាប័នមួយទៅកាន់ភាគីពាក់ព័ន្ធ រួមទាំងការគ្រប់គ្រង វិនិយោគិន ម្ចាស់បំណុល និងភ្នាក់ងារនិយតកម្ម[19]។

**របាយការណ៍ហិរញ្ញវត្ថុ** មានគោលបំណងតាមដាន វិភាគ និងរាយការណ៍ចំណូលអាជីវកម្មរបស់អ្នក និងវិនិយោគិនណាម្នាក់ធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹងអំពីរបៀបគ្រប់គ្រងអាជីវកម្ម[20]។

### ២.៣.២ ប្រវត្តិនៃទ្រព្យសកម្ម និងរបាយការណ៍ហិរញ្ញវត្ថុ

- **ប្រវត្តិនៃទ្រព្យសកម្ម**

ចាប់ពីថ្ងៃដំបូងនៃអរិយធម៌របស់មនុស្ស ការយល់ដឹងអំពីតម្លៃរបស់យើងបានបង្ហាញពីរបៀបដែលយើងប្រាស្រ័យទាក់ទងជាមួយពិភពលោក។ គោលគំនិតនៃទ្រព្យសកម្ម ឬធនធានដែលរក្សាទុក ឬតម្លៃដែលយល់ឃើញបានឆ្លងកាត់ពីការផ្លាស់ប្តូររាប់មិនអស់ នៅពេលដែលសង្គម និងសេដ្ឋកិច្ចមានការវិវត្ត។ សព្វថ្ងៃ

---

[14] Mathnmoney. Sokchea Pheourk (2018, September 18). *តើអ្វីទៅជា "ទ្រព្យសកម្ម ឬActive Asset"?* Retrieved from https://math-nmoney.blogspot.com/2018/09/active-asset.html

[15] Buykhmerbook. (2021, August 23). *តើពាក្យ «ទ្រព្យសកម្ម» មានន័យដូចម្តេច?* Retrieved from https://buykhmerbook.com/ar-chives/105342

[16] Investopedia. The Investopedia Team (Update 2025, October 15). *What Is an Asset? Definition, Types, and Examples.* Retrieved from https://www.investopedia.com/terms/a/asset.asp

[17] Indeed. Lauren Oliver, B.Ed., (2025, June 07). *What Is Financial Reporting? Definition, Types and Importance*. https://www.in-deed.com/career-advice/career-development/what-is-financial-reporting

[18] wikipedia (2025, June 16). *Financial statement.* Retrieved from https://en.wikipedia.org/wiki/Financial_statement

[19] Gartner. *Financial Reporting*. Retrieved May, 20 2025 from https://www.gartner.com/en/finance/glossary/financial-reporting

[20] Xero. *What is financial reporting?* Retrieved May, 20 2025 from https://www.xero.com/glossary/financial-reporting

នេះយើងរស់នៅក្នុងពិភពលោកមួយ ដែលទ្រព្យសម្បត្តិអាចបង្កើតទម្រង់ជាច្រើន ពីវត្ថុជាក់ស្តែង ដូចជា អចលនទ្រព្យ និងលោហៈដ៏មានតម្លៃ រហូតដល់ការបង្កើតអរូបី ដូចជាកម្មសិទ្ធិបញ្ញា និងរូបិយប័ណ្ណឌីជីថល ជាដើម។ នៅក្នុងដំណើរដ៏គួរឱ្យចាប់អារម្មណ៍នេះតាមរយៈប្រវត្តិសាស្ត្រនៃទ្រព្យសកម្ម យើងនឹងស្វែងយល់ពី របៀបដែលការយល់ឃើញរបស់យើងអំពីតម្លៃបានផ្លាស់ប្តូរតាមពេលវេលា ហើយហេតុអ្វីបានជាការយល់ដឹង អំពីការវិវត្តន៍នេះមានសារៈសំខាន់ចំពោះការសម្រេចចិត្តប្រកបដោយការយល់ដឹងនៅក្នុងទិដ្ឋភាពផ្លាស់ប្តូរយ៉ាង ឆាប់រហ័សនាពេលបច្ចុប្បន្ននេះ។

## ១. ប្រភពដើមនៃទ្រព្យសកម្ម

ស្រមៃមើលពិភពលោកដែលគ្មានលុយ ដែលទំនិញ និងសេវាកម្មត្រូវបានផ្លាស់ប្តូរដោយផ្ទាល់ដែល ផ្អែកលើតម្រូវការ និងកិច្ចព្រមព្រៀងទៅវិញទៅមក។ នេះគឺជាការពិតនៅក្នុងសង្គមមនុស្សសម័យដើម ដែល ការដោះដូរបានចាក់គ្រឹះសម្រាប់គំនិតនៃទ្រព្យសកម្ម។ នៅក្នុងប្រព័ន្ធមូលដ្ឋាននេះ មនុស្សមានការជួញដូរ ទំនិញដូចជា សត្វ គ្រាប់ធញ្ញជាតិ និងឧបករណ៍ ដោយកំណត់តម្លៃដល់ទំនិញដែលជាក់ស្តែងទាំងនេះ ដោយផ្អែកលើឧបករណ៍ប្រើប្រាស់ និងកង្វះខាតភ្លាមៗរបស់ពួកគេ។

-**ការដោះដូរ** ការអនុវត្តនៃការដោះដូរមានតាំងពីរាប់ពាន់ឆ្នាំមុន ជាមួយនឹងភស្តុតាងនៃការប្រើប្រាស់របស់វា ត្រូវបានរកឃើញនៅក្នុងវប្បធម៌បុរាណនៅទូទាំងពិភពលោក។ ប្រព័ន្ធនេះបានអនុញ្ញាតឱ្យបុគ្គលផ្លាស់ប្តូរទំនិញ និងសេវាកម្មដោយផ្អែកលើជំនាញ និងធនធានតែមួយគត់របស់ពួកគេ ជំរុញកិច្ចសហប្រតិបត្តិការ និង ពាណិជ្ជកម្មនៅក្នុងសហគមន៍ ទោះយ៉ាងណាក៏ដោយ ការដោះដូរមានដែនកំណត់របស់វា។

-**ការលេចឡើងនៃរូបិយប័ណ្ណ** ប្រហែល 5,000 ឆ្នាំមុន យើងបានឃើញកំណើតនៃរូបិយប័ណ្ណ ដែលជាការ ច្នៃប្រឌិតដ៏ល្អឥតខ្ចោះ ដែលបានធ្វើបដិវត្តន៍ពីរបៀបដែលមនុស្សយល់ឃើញពីតម្លៃ។ ទម្រង់រូបិយប័ណ្ណដំបូង ដូចជាកាក់ដែក និងសំបក បានផ្តល់រង្វាស់តម្លៃស្តង់ដា ដែលជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មលើទំហំធំជាង។ រូបិយប័ណ្ណទាំងនេះអាចចល័តបាន បែងចែក និងទទួលយកបានយ៉ាងទូលំទូលាយ ដែលធ្វើឱ្យវាកាន់តែ ងាយស្រួលសម្រាប់មនុស្សដើម្បីធ្វើប្រតិបត្តិការ និងប្រមូលទ្រព្យសម្បត្តិ។ នៅពេលដែលសង្គមកាន់តែមាន ភាពស្មុគស្មាញ និងទំនាក់ទំនងគ្នាទៅវិញទៅមក ការវិវត្តនៃរូបិយប័ណ្ណបានបង្កើនល្បឿន ដែលនៅទីបំផុតនាំ ទៅដល់ការអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុទំនើប។ ការលេចចេញនៃរូបិយប័ណ្ណបានពង្រីកអាណាចក្រនៃទ្រព្យ លើសពីទំនិញដែលអាចរកបាន និងបានដាក់មូលដ្ឋានគ្រឹះសម្រាប់អារេដ៏ទំនើបនៃទ្រព្យសកម្មដែលយើង ទទួលស្គាល់សព្វថ្ងៃនេះ។

## ២. ការកើនឡើងនៃទ្រព្យសកម្ម

នៅពេលដែលសង្គមបានបន្តរីកចម្រើន និងរីកចម្រើន គំនិតនៃទ្រព្យសម្បត្តិបានពង្រីកហួសពីអាណា ចក្រនៃរូបិយប័ណ្ណ និងលោហៈដ៏មានតម្លៃ។ ការលេចឡើងនៃទ្រព្យសម្បត្តិរូបីដូចជាអចលនទ្រព្យ សិល្បៈ និងការប្រមូលបានបន្ថែមវិមាត្រថ្មីដល់ការយល់ដឹងរបស់យើងអំពីតម្លៃ បង្កើតឱកាសសម្រាប់បុគ្គលក្នុងការ វិនិយោគ និងប្រមូលទ្រព្យសម្បត្តិតាមរបៀបចម្រុះ។

-**អចលនទ្រព្យ** គឺជាមូលដ្ឋានគ្រឹះនៃទ្រព្យសម្បត្តិ និងឋានៈសង្គមពេញមួយប្រវត្តិសាស្ត្រ ដោយកម្ម សិទ្ធិដីធ្លីជារឿយៗតំណាងឱ្យអំណាច កិត្យានុភាព និងស្ថិរភាព។ អចលនទ្រព្យដ៏ធំទូលាយនៃពួកអភិជនរ៉ូម៉ាំង បុរាណ រហូតដល់វិមានដ៏ប្រណិតនៃយុគសម័យ Gilded ការកាន់កាប់អចលនទ្រព្យគឺជាសញ្ញានៃភាពជោគជ័យ

និងទ្រព្យសម្បត្តិតាំងពីយូរយារណាស់មកហើយ។ ទោះជាយ៉ាងណាក៏ដោយ ការអំពាវនាវដ៏យូរអង្វែងរបស់អចលនទ្រព្យដែលមានតម្លៃនៅខាងក្នុងនៃអចលនទ្រព្យនោះ។ ធនធានដែលមានកំណត់ ដូចជាដីកាន់តែមានតម្លៃ ដោយសារចំនួនប្រជាជនកើនឡើង។ ជាលទ្ធផល ការវិនិយោគលើអចលនទ្រព្យបានក្លាយជាយុទ្ធសាស្ត្រដ៏ពេញនិយមមួយសម្រាប់ការរក្សាទ្រព្យសម្បត្តិ និងកំណើន ដែលផ្តល់ទាំងប្រាក់ចំណូលហិរញ្ញវត្ថុ និងអារម្មណ៍នៃភាពជាម្ចាស់ជាក់ស្តែង។

### ៣. ភាគហ៊ុន និងប័ណ្ណបំណុល

នៅពេលដែលសេដ្ឋកិច្ចពិភពលោកកាន់តែមានភាពស្មុគស្មាញ និងទំនាក់ទំនងគ្នាទៅវិញទៅមក ទ្រព្យសកម្មប្រភេទថ្មីបានលេចឡើងដើម្បីដោះស្រាយភាពស្មុគស្មាញនៃពាណិជ្ជកម្ម និងការវិនិយោគដែលកំពុងកើនឡើង៖ ទ្រព្យសម្បត្តិហិរញ្ញវត្ថុ។ ភាគហ៊ុន និងមូលបត្របំណុល ដែលជាមូលដ្ឋានគ្រឹះនៃទីផ្សារហិរញ្ញវត្ថុទំនើប បានផ្លាស់ប្តូររបៀបដែលយើងយល់ឃើញ និងទំនាក់ទំនងជាមួយតម្លៃ ដែលអនុញ្ញាតឱ្យបុគ្គល និងស្ថាប័នចូលរួមនៅក្នុងការរីកចម្រើន និងភាពជោគជ័យនៃអាជីវកម្ម និងរដ្ឋាភិបាល។

### ៤. កម្មសិទ្ធិបញ្ញា

ក្នុងយុគសម័យទំនើប ការយល់ឃើញអំពីរបស់មានតម្លៃយើងបានពង្រីកបន្ថែមទៀតដើម្បីរួមបញ្ចូលទ្រព្យសកម្មអរូបី ដែលមានតម្លៃមិននៅក្នុងទម្រង់រូបវន្តរបស់ពួកគេ ប៉ុន្តែនៅក្នុងគំនិត ការច្នៃប្រឌិត និងកេរ្តិ៍ឈ្មោះដែលពួកគេតំណាង។ កម្មសិទ្ធិបញ្ញា និងម៉ាកយីហោគឺជាឧទាហរណ៍ចម្បងនៃទ្រព្យសម្បត្តិអរូបី ដែលបង្កើតឧស្សាហកម្ម និងសេដ្ឋកិច្ចយ៉ាងជ្រាលជ្រៅ[21]។

- **ប្រវត្តិនៃរបាយការណ៍ហិរញ្ញវត្ថុ**

នៅក្នុងសតវត្សទី17 អាជីវកម្មនៅក្នុងប្រទេសបារាំងបានរាយការណ៍ជាសាធារណៈតាមរយៈតារាងតុល្យការប្រចាំឆ្នាំ ដែលជារង្វាស់នៃទ្រព្យសកម្ម និងបំណុលដែលមានគោលបំណងការពារការក្ស័យធន។ ពួកគេមិនសូវជឿនលឿន និងស្តង់ដាដាងសព្វថ្ងៃនោះទេ គោលដៅចម្បងរបស់ពួកគេគឺគោរពតាមបទប្បញ្ញត្តិរបស់រដ្ឋាភិបាល និងជានាស្ថិរភាពហិរញ្ញវត្ថុនៃអាជីវកម្ម និងប្រទេស។ ក្នុងរយៈពេលជាច្រើនសតវត្សរ៍បន្ទាប់ គណនេយ្យបានបន្តវិវឌ្ឍន៍ ប៉ុន្តែការបោះផ្សាយគណនីនៅតែផ្តោតលើការការពារការក្ស័យធន។ នៅអំឡុងសតវត្សរ៍ទី 20 ដែលគណនេយ្យបានឆ្លងកាត់ការផ្លាស់ប្តូរសំខាន់ៗ វាកាន់តែស្មុគស្មាញ ហើយចាប់ផ្តើមរួមបញ្ចូលស្តង់ដា និងបទប្បញ្ញត្តិគណនេយ្យកាន់តែទំនើប ហើយឥឡូវនេះរួមបញ្ចូលទិដ្ឋភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ។

ស្តង់ដា IFRS (International Financial Reporting Standards) អន្តរជាតិគឺជាការវិវត្តន៍មួយក្នុងចំណោមការវិវត្តន៍ទាំងនោះ ពាក្យស្នើសុំរបស់ពួកគេនៅក្នុងទ្វីបអឺរ៉ុបត្រូវបានបញ្ជាក់ដោយបទប្បញ្ញត្តិ (EC European Community) លេខ1606/2002 ដែលត្រូវបានគេស្គាល់ថាជា "បទប្បញ្ញត្តិ IAS ( International Accounting Standards" សម្រាប់ស្តង់ដាគណនេយ្យអន្តរជាតិ ដែលបានបោះពុម្ពនៅថ្ងៃទី 19 ខែកក្កដា ឆ្នាំ 2002។ ការអនុវត្តស្តង់ដារថ្មីទាំងនេះបានសម្គាល់ចំណុចដ៏សំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលមានបំណងធ្វើឱ្យមានភាពស៊ីសង្វាក់គ្នានៃគុណភាពនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុលើមាត្រដ្ឋានសក

[21] maxwellinvestmentsgroup (2023, Apr 15) *A Brief History of "ASSETS": How Our Perception of Value Has Changed.* Retrieved from https://maxwellinvestmentsgroup.com/2023/04/a-brief-history-of-assets-how-our-perception-of-value-has-changed

ល។ គំនិតផ្តួចផ្តើមនេះបានធ្វើឱ្យមានភាពសាមញ្ញយ៉ាងខ្លាំងក្នុងការប្រៀបធៀបរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសផ្សេងៗ ដោយហេតុនេះបានបង្កើនតម្លាភាព និងការយល់ដឹងអំពីប្រតិបត្តិការហិរញ្ញវត្ថុ។ បន្ទាប់ពីការណែនាំស្តង់ដាគណនេយ្យអន្តរជាតិ IFRS និង URD (Universal Registration Document) បានបញ្ចប់ការផ្លាស់ប្តូរដ៏សំខាន់នេះនៅក្នុងតម្លាភាពហិរញ្ញវត្ថុ។ IFRS បានបង្កើតក្របខ័ណ្ឌទូទៅមួយសម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ខណៈដែល URD សម្រួលនីតិវិធីបញ្ចេញព័ត៌មាន ដែលអនុញ្ញាតឱ្យក្រុមហ៊ុនបោះផ្សាយឯកសារដែលអនុលោមតាម IFRS តែមួយសម្រាប់ទីផ្សារអឺរ៉ុបទាំងអស់ដែលពួកគេត្រូវបានចុះបញ្ជី។ ភាពស៊ីសង្វាក់គ្នារវាង IFRS និង URD នេះបានធ្វើឱ្យការបញ្ចេញព័ត៌មានហិរញ្ញវត្ថុមានភាពសាមញ្ញយ៉ាងសំខាន់ ដោយហេតុនេះធ្វើអោយប្រសើរឡើងនូវលទ្ធភាពទទួលបានទិន្នន័យសំខាន់ៗរបស់អ្នកវិនិយោគ និងពង្រឹងទំនុកចិត្តនៅក្នុងទីផ្សារហិរញ្ញវត្ថុរបស់សហភាពអឺរ៉ុប។

លក្ខណៈសំខាន់ៗរបស់ URD បានបង្កើតឡើងដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុនបោះផ្សាយឯកសារតែមួយដែលបំពេញតាមលក្ខខណ្ឌនៃការបង្ហាញព័ត៌មានសម្រាប់ទីផ្សារអឺរ៉ុបទាំងអស់ដែលពួកគេត្រូវបានចុះបញ្ជី។ លក្ខណៈសំខាន់ៗបំផុតមានដូចជា៖

-ភាពស៊ីសង្វាក់គ្នា ៖ ធានាថាព័ត៌មានសំខាន់ៗត្រូវបានបង្ហាញជាប់លាប់។

-ងាយស្រួលចូលប្រើព័ត៌មាន

-ភាពសាមញ្ញនៃដំណើរការបញ្ចេញព័ត៌មាន៖ ធ្វើឱ្យដំណើរការបញ្ចេញព័ត៌មានហិរញ្ញវត្ថុមានភាពសាមញ្ញ និងសំខាន់សម្រាប់ក្រុមហ៊ុនដែលបានចុះបញ្ជី។

-ការកាត់បន្ថយថ្លៃដើម និងការសន្សំពេលវេលា៖ អាជីវកម្មអាចកាត់បន្ថយការចំណាយលើការអនុលោមតាម ខណៈពេលដែលបង្កើនល្បឿនដំណើរការរាយការណ៍។

-ការអនុលោមតាម IFRS និង XBRL៖ ការអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិ (IFRS) និងការប្រើប្រាស់ភាសា XBRL (extensible Business Reporting Language) សម្រាប់របាយការណ៍ហិរញ្ញវត្ថុធានាបាននូវការតម្រឹមជាមួយនឹងការអនុវត្តល្អបំផុតគណនេយ្យសកល និងសម្របសម្រួលការវិភាគ និងដំណើរការទិន្នន័យហិរញ្ញវត្ថុ[22]។

**២.៣.៣ ទ្រឹស្តីនៃទ្រព្យសកម្ម**

ទ្រឹស្តីនៃទ្រព្យសកម្មគួរតែពណ៌នាអំពីប្រភពដើមជីវិត និងការចូលនិវត្តន៍នៃទ្រព្យសម្បត្តិជាទូទៅនៅក្នុងពាក្យ ទ្រព្យសកម្ម គួរតែត្រូវបានកំណត់ គ្រប់គ្រាន់ដើម្បីរួមបញ្ចូលលក្ខណៈសំខាន់ៗសម្រាប់វិស័យផ្សេងៗក្នុងការគ្រប់គ្រងពាណិជ្ជកម្ម សេដ្ឋកិច្ច និងវិស័យឧស្សាហកម្ម ហើយវាក៏គួរតែរួមបញ្ចូលលក្ខណៈដែល ប្រើប្រាស់នាពេលអនាគតសម្រាប់ក្រុមហ៊ុន។ ដោយយោងតាមទ្រឹស្តីទៅតាមសកលវិទ្យាល័យមួយចំនួនបាននិយាយថា៖ ពិភពលោកដែលយើងរស់នៅបាន ស្គាល់ថាជាចក្រវាឡដែលផ្ទុកមនុស្ស សត្វ គំនិត សម្លៀកបំពាក់ ផ្ទះ យន្តហោះ ឡាន។ វត្ថុជាវត្ថុណាមួយដែលរូបី ឬអរូបី មានចលនា ឬគ្មានជីវិត មានសមត្ថភាពបម្រើសេវាកម្ម និងទាមទារការថែទាំ។ អ្វីគ្រប់យ៉ាងគឺជាវត្ថុមួយអាចជាទ្រព្យសម្បត្តិ ប៉ុន្តែមិនមែនវត្ថុទាំងអស់ជាទ្រព្យសម្បត្តិនោះទេ។ ដើម្បីឱ្យវត្ថុក្លាយជាទ្រព្យសកម្ម វាត្រូវបំពេញតាមលក្ខខណ្ឌដើម្បីជាទ្រព្យសកម្ម ជាក់

[22] Pomelo-Paradigm. (2023, October 19). *The story of financial reporting*. Retrieved from https://www.pomelo-paradigm.com/story-financial-reporting-urd

ស្តែងវត្ថុត្រូវតែមានសមត្ថភាពបំពេញតម្រូវការមួយចំនួន មានលទ្ធភាពសេដ្ឋកិច្ច មុនពេលវត្ថុមួយជាទ្រព្យសកម្មគ្រប់លក្ខខណ្ឌ។ ទ្រព្យសកម្ម គឺជាទ្រព្យសកម្មដែលទាក់ទងនឹងបុគ្គល ឬអង្គភាពណាមួយប៉ុណ្ណោះ។ សម្រាប់បុគ្គលពិភពលោកគឺពោរពេញទៅដោយវត្ថុៗទាំងនេះមួយចំនួនតូចជាទ្រព្យរបស់បុគ្គល វត្ថុជាច្រើនទៀតជាទ្រព្យរបស់បុគ្គលដទៃ ហើយវត្ថុខ្លះនៅតែជាទ្រព្យរបស់បុគ្គល។ ឧទាហរណ៍វត្ថុខ្លះដែលគេចាត់ទុកជាទ្រព្យដោយគ្មានម្ចាស់គឺ រ៉ែនៅបាតសមុទ្រ គំនិតឥតគិតថ្លៃ ការច្នៃប្រឌិត ដំណើរការ និងខ្យល់ជាដើម។ វត្ថុទាំងអស់ដែលគ្រប់គ្រងដោយក្រុមហ៊ុនត្រូវបានចាត់ទុកថាជាទ្រព្យសម្បត្តិ រួមទាំងវត្ថុដែលមានតម្លៃអវិជ្ជមាននៅពេលដែលវាច្បាស់ថាតម្លៃទ្រព្យសកម្មយោងទៅតាមប្រព័ន្ធវាយតម្លៃពាក់ព័ន្ធក្នុងការសម្រេចចិត្តទៅលើតម្លៃអវិជ្ជមាន អាចរក្សាជាទ្រព្យសកម្ម ឬផ្លាស់ប្តូរនៃការប្រើប្រាស់របស់វា (ប្រសិនបើវានឹងទទួលបានផលចំណេញ) ចូលនិវត្តន៍ទ្រព្យសម្បត្តិតាមរយៈការលក់ ឬសំណល់អេតចាយ។ ដោយសារមនុស្សជាផ្នែកមួយនៃសកលលោកនៃវត្ថុ វាជាការគួរឱ្យចាប់អារម្មណ៍ក្នុងការកត់សម្គាល់ថាតើពួកគេជាទ្រព្យសម្បត្តិឬក៏អត់ មិនមែនជាសំណួរទ្រឹស្តីទេ ប៉ុន្តែជាសំណួរសង្គម។ ដើម្បីក្លាយជាទ្រព្យ វត្ថុត្រូវតែជាកម្មសិទ្ធិប្រសិនបើសង្គមមិនអនុញ្ញាតឱ្យមានកម្មសិទ្ធិរបស់មនុស្សទេនោះ មនុស្សមិនអាចក្លាយជាទ្រព្យសម្បត្តិបានទេ។ ខណៈពេលដែលសេវាកម្មរបស់បុគ្គលអាចត្រូវបានទិញដោយកិច្ចសន្យា ទាំងបុគ្គល ឬសេវាកម្មរបស់គាត់មិនមែនជាកម្មសិទ្ធិនោះទេ មានតែសិទ្ធិលើសេវាកម្មរបស់បុគ្គលនោះ ក្រោមលក្ខខណ្ឌជាក់លាក់ណាមួយដែលបានបញ្ជាក់ជាកម្មសិទ្ធិ ដូច្នេះកិច្ចសន្យាសម្រាប់សេវាកម្មរបស់បុគ្គលម្នាក់ដែលអាចជាកម្មសិទ្ធិគឺជាទ្រព្យសកម្មមួយ។ ការពេញចិត្តនៃការចង់បាន ឬតម្រូវការ គឺជាហេតុផលសម្រាប់ការទទួលបាន និងការប្រើប្រាស់ទ្រព្យសម្បត្តិ។ ទ្រព្យសម្បត្តិមួយចំនួនដូចជាសម្លៀកបំពាក់ អាហារ ទីជម្រក មធ្យោបាយធ្វើដំណើរ និងសៀវភៅ ទ្រព្យសម្បត្តិផ្សេងទៀតបំពេញការចង់បានដោយប្រយោល ពួកគេគឺជាមធ្យោបាយមួយដើម្បីចង់បានការពេញចិត្ត។ ឡានដឹកទំនិញ រោងចក្រ ឬអាជីវកម្មក៏ជាទ្រព្យសម្បត្តិដែលបន្ថែមពីលើការបំពេញនូវបំណងប្រាថ្នាសម្រាប់ការកាន់កាប់ អំណាច ឬឯករាជ្យ ទ្រព្យសម្បត្តិទាំងនេះផលិតសេវាកម្មផ្សេងទៀត ឬរួមបញ្ចូលគ្នាជាមួយទ្រព្យសម្បត្តិផ្សេងទៀត ដែលហៅថាទិន្នផលរូបវន្ត។ ទិន្នផលនេះអាចត្រូវបានផ្លាស់ប្តូរជាប្រាក់ ហើយប្រាក់ទាំងនេះអាចត្រូវបានប្រើដើម្បីទទួលបានទ្រព្យសម្បត្តិសម្រាប់ការពេញចិត្តផ្ទាល់ខ្លួន ឬតម្រូវការអាជីវកម្ម។

សេវាកម្មនៃទ្រព្យសកម្ម និងវត្ថុទាំងនេះមានតម្លៃដោយតម្លៃនេះអាចជាវិជ្ជមាន អវិជ្ជមាន ឬសូន្យ ហើយវានឹងប្រែប្រួលអ្វីៗផ្សេងទៀតមានភាពស្មើគ្នាជាមួយនឹងរបៀបដែលទ្រព្យសកម្មត្រូវបានប្រើប្រាស់ ដែលសេវាកម្មមានសក្តានុពលក្លាយជាសេវាកម្មដែលយល់ឃើញ។ សេវាកម្មផ្សេងៗគ្នា មានតម្លៃខុសៗគ្នា ទាំងតម្លៃ និងប្រាក់ចំណូល ហើយនេះនឹងឆ្លុះបញ្ចាំងពីតម្លៃខុសគ្នាសម្រាប់ការប្រើប្រាស់ទ្រព្យសកម្មនីមួយ[23]។

### ២.៣.៤ សារៈសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពប្រកបដោយតម្លាភាព និងត្រឹមត្រូវនៃទីតាំងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុន ដូចជាការគ្រប់គ្រង វិនិយោគិន អ្នកផ្តល់ប្រាក់កម្ចី និងអាជ្ញាធរគ្រប់គ្រង ប្រើប្រាស់ឯកសារទាំងនេះ ដែលត្រូវបានរៀបចំតាមកាលកំណត់ ដើម្បីវាយតម្លៃប្រតិបត្តិការហិរញ្ញវត្ថុរបស់ពួកគេ និងចាត់វិធានការចាំបាច់។ ខាងក្រោមនេះគឺជាហេតុផលដែលពិពណ៌នាអំពីសារៈសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ៖

[23] ACADEMIA. ELIJAH OSIANOR.*UTHEORY OF ASSETS IN ACCOUNTING.* Retrieved May, 25 2025 from https://www.academia.edu/10948664/THEORY_OF_ASSETS_IN_ACCOUNTING

- **ការសម្រេចចិត្តសម្រាប់ការគ្រប់គ្រង៖** របាយការណ៍ហិរញ្ញវត្ថុអាចផ្តល់ព័ត៌មានលម្អិតអំពីរបៀបដែលក្រុមហ៊ុនកំពុងដំណើរការ របាយការណ៍ប្រាក់ចំណូល និងរបាយការណ៍លំហូរសាច់ប្រាក់បង្ហាញពីប្រាក់ចំណេញរបស់ក្រុមហ៊ុន ចំណែកតារាងតុល្យការបង្ហាញព័ត៌មានលម្អិតអំពីសាច់ប្រាក់ងាយស្រួល និងជំណោះស្រាយ។ ដោយប្រើសេចក្តីថ្លែងការណ៍ទាំងនេះ អ្នកគ្រប់គ្រងអាចសម្រេចចិត្តលើការវិនិយោគនាពេលអនាគត ការកាត់បន្ថយថ្លៃដើម និងការកែលម្អប្រតិបត្តិការ ដោយសារពួកគេនឹងមានគំនិតអំពីស្ថានភាពបច្ចុប្បន្ននៃអាជីវកម្ម។
- **ទំនុកចិត្តរបស់វិនិយោគិន៖** របាយការណ៍ហិរញ្ញវត្ថុជួយអោយអ្នកវិនិយោគិនវាយតម្លៃពីភាពរឹងមាំរបស់ក្រុមហ៊ុន ពួកគេអាចឆ្លើយសំណួរដូចជា៖ តើក្រុមហ៊ុនកំពុងដំណើរការដោយប្រយ័ត្នប្រយែងប៉ុណ្ណា ទីតាំងរឹងមាំប៉ុណ្ណាដើម្បីរស់រានមានជីវិត និងប្រសិនបើវាមានលទ្ធភាពរីកចម្រើន។ វាអាចជួយអ្នកវិនិយោគក្នុងការសម្រេចចិត្តថាតើត្រូវទិញ កាន់ ឬលក់ ហើយប្រសិនបើដូច្នេះ តើមានតម្លៃប៉ុន្មាន។ ក្រុមហ៊ុនដែលមានហិរញ្ញវត្ថុល្អ និងស្អាតស្អំ ជំរុញឱ្យមានទំនុកចិត្ត និងការជឿទុកចិត្តកាន់តែច្រើន ដែលធ្វើឱ្យវាកាន់តែងាយស្រួលក្នុងការរៃអង្គាសប្រាក់ពីអ្នកវិនិយោគិន ធនាគារ និងភាគហ៊ុនឯកជន។
- **ការអនុលោមតាមបទប្បញ្ញត្តិ៖** ក្រុមហ៊ុននៅស្ទើរតែគ្រប់ប្រទេសត្រូវបានបង្ខំដោយច្បាប់ដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមកាលកំណត់ ដែលត្រូវតែអនុលោមតាមស្តង់ដាគណនេយ្យដែលកំណត់ដោយអាជ្ញាធរហិរញ្ញវត្ថុ។ នេះនាំទៅដល់ការបង្កើតរបាយការណ៍ហិរញ្ញវត្ថុដែលមានបំណងផ្តល់នូវទិដ្ឋភាពពិត និងយុត្តិធម៌នៃទីតាំងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន វាជួយរក្សាភាពសុចរិតនៅក្នុងទីផ្សារហិរញ្ញវត្ថុ និងការពារអ្នកពាក់ព័ន្ធដោយស្របច្បាប់។
- **សម្រាប់អ្នកផ្តល់ប្រាក់កម្ចី៖** នៅពេលដែលក្រុមហ៊ុនដាក់ពាក្យស្នើសុំកម្ចី ឬឧបករណ៍ឥណទានផ្សេងទៀតពីធនាគារ ឬស្ថាប័នហិរញ្ញវត្ថុ ពួកគេពិនិត្យមើលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះមុនពេលអនុម័ត ឬបដិសេធសំណើនេះ។ របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំយ៉ាងល្អជួយអ្នកឱ្យខ្ចីដើម្បីវាយតម្លៃសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការសងប្រាក់កម្ចីរបស់ខ្លួន គ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងរក្សាសាច់ប្រាក់ឱ្យបានគ្រប់គ្រាន់ដើម្បីបន្តអាជីវកម្ម ដោយផ្អែកលើទិន្នន័យនេះពួកគេនឹងកំណត់កម្រិតនៃហានិភ័យដែលពាក់ព័ន្ធ និងលក្ខខណ្ឌនៃការផ្តល់ប្រាក់កម្ចី។
- **ការដាក់ពិន្ទុ និងវាយតម្លៃការអនុវត្ត៖** របាយការណ៍ហិរញ្ញវត្ថុអនុញ្ញាតឱ្យអាជីវកម្មវាស់វែងលទ្ធផលរបស់ពួកគេធៀបនឹងស្តង់ដាឧស្សាហកម្ម មិត្តភ័ក្តិ និងដៃគូប្រកួតប្រជែង។ ដោយផ្តោតលើសមាមាត្រហិរញ្ញវត្ថុ និងប្រៀបធៀបពួកគេជាមួយក្រុមហ៊ុនផ្សេងទៀតនៅក្នុងឧស្សាហកម្មដូចគ្នា អាចជួយឱ្យអាជីវកម្មស្វែងរកចំណុចខ្លាំង និងចំណុចខ្សោយរបស់ពួកគេ និងស្វែងរកលទ្ធភាពដើម្បីអភិវឌ្ឍខ្លួនឯង។ ការត្រួតពិនិត្យការអនុវត្តជាប្រចាំអនុញ្ញាតឱ្យអាជីវកម្មមានចេតនា និងយុទ្ធសាស្ត្រកាន់តែច្រើនក្នុងការសម្រេចចិត្តរបស់ពួកគេ។
- **ការអនុលោមតាមច្បាប់៖** របាយការណ៍ហិរញ្ញវត្ថុមានប្រយោជន៍សម្រាប់ការធ្វើផែនការពន្ធ ពោលគឺពួកគេជួយអោយអាជីវករយល់ពីការទទួលខុសត្រូវពន្ធរបស់ខ្លួន និងរបៀបកាត់បន្ថយវិក្កយបត្រពន្ធរបស់ខ្លួន។ នៅ

ពេលបង្ហាញជាមួយនឹងរូបភាពត្រឹមត្រូវនៃកម្រិតចំណូល និងចំណាយ របាយការណ៍ហិរញ្ញវត្ថុជួយអាជីវកម្ម ក្នុងការរៀបចំសម្រាប់ការដាក់ពន្ធ ក៏ដូចជាការធានាថាវាបំពេញតាមក្របខ័ណ្ឌពន្ធ[24]។

[24] Enkash. (2024, October 30). *Financial Statements: Meaning, Importance, Benefits, Scope and Objectives*. Retrieved from https://www.enkash.com/resources/blog/financial-statements-meaning-importance-benefits-scope-and-objectives

# ជំពូកទី៣
# សារៈសំខាន់ស្តង់ដាគណនេយ្យនៃអន្តរជាតិនៃកម្ពុជា២

## ៣.១ ស្ថានភាពទូទៅនៃនិយ័តករគណនេយ្យនិងសវនកម្ម

និមិត្តសញ្ញាចាស់ និមិត្តសញ្ញាបច្ចុប្បន្ន

និយ័តករគណនេយ្យនិងសវនកម្ម (Accounting and Auditing Regulator - ACAR) នៅកម្ពុជា ដើរតួនាទីយ៉ាងសំខាន់ក្នុងការធានានូវតម្លាភាពហិរញ្ញវត្ថុ និងភាពអាចទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុន និងអង្គភាពនានា។ ACAR គឺជាស្ថាប័នរដ្ឋបាលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (Non-Bank Financial Services Authority) និងជាផ្នែកមួយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ៣.១.១ ប្រវត្តិនៃនិយ័តករគណនេយ្យនិងសវនកម្ម

ដំបូងឡើយនិយ័តករគណនេយ្យនិងសវនកម្មត្រូវបានគេស្គាល់ថាជាក្រុមប្រឹក្សាជាតិគណនេយ្យដែលមានអក្សរកាត់ ក.ជ.គ ដែលស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវបានបង្កើតឡើងនៅខែមីនា ឆ្នាំ 2003 ដើម្បីត្រួតពិនិត្យ និងកំណត់ស្តង់ដាគណនេយ្យ និងសវនកម្ម។ ក្រុមប្រឹក្សាជាតិគណនេយ្យបានអនុម័តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ជាស្តង់ដាកម្ពុជា (CIFRS)។ យោងតាម ព្រះរាជក្រមលេខ នសរកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ ២០២១ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការ រៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ" ក្រុមប្រឹក្សាជាតិគណនេយ្យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានធ្វើសមាហរណកម្មទៅក្នុង អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារក្រោមឈ្មោះថា និយ័តករគណនយ្យនិងសវនកម្ម។ និយ័តករគណនេយ្យនិងសវនកម្ម នឹងបន្តអនុវត្ត មុខងារភារកិច្ចរបស់ក្រុមប្រឹក្សាជាតិគណនេយ្យដែលបានកំណត់នៅក្នុង ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

### ៣.១.២ បេសកកម្ម និងទស្សនវិស័យរបស់និយ័តករគណនេយ្យនិងសវនកម្ម

**ក. បេសកកម្ម**

និយ័តករគណនេយ្យនិងសវនកម្ម (សរសេរកាត់ថា ន.គ.ស.) បំពេញមុខងារជាសេនាធិការឱ្យ អ.ស.ហ. ក្នុងការគ្រប់គ្រងនិងអភិវឌ្ឍវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា តាមរយៈការដាក់ចេញនូវបទប្បញ្ញត្តិ វិធាន និងស្តង់ដា ព្រមទាំងជំរុញការអនុវត្តច្បាប់និងស្តង់ដាគណនេយ្យនិងសវនកម្មកម្ពុជា។

**ខ. ទស្សនវិស័យ**

និយ័តករគណនេយ្យនិងសវនកម្ម នឹងក្លាយជាស្ថាប័ននិយ័តករដែលមានសមត្ថភាព និងគុណតម្លៃវិជ្ជាជីវៈ ព្រមទាំងមានកិច្ចដំណើរការប្រកបដោយនិរន្តភាព និងគណនេយ្យភាព ដោយទទួលបាននូវការទុកចិត្តពីរាជរដ្ឋាភិបាល វិស័យឯកជន និងតួអង្គ ពាក់ព័ន្ធ ក្នុងការគ្រប់គ្រងវិស័យគណនេយ្យនិងសវនកម្ម ដើម្បីទ្រទ្រង់និងគាំពារការអភិវឌ្ឍលើគ្រប់វិស័យ ពិសេសវិស័យហិរញ្ញវត្ថុ សំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាពនិងបរិយាប័ន្ន។

### ៣.១.៣ រចនាសម្ព័ន្ធនៃនិយ័តករគណនេយ្យនិងសវនកម្ម




**រចនាសម្ព័ន្ធនៃការគ្រប់គ្រង**

- ឯកឧត្តម ប៊ូ ថារិន អគ្គនាយក
- លោក ជា ចាន់ថា អគ្គនាយករង
- លោក ជេន ផាត អគ្គនាយករង
- លោកស្រី នាន បូនី អគ្គនាយករង

**៣.២.៤ នាយកដ្ឋាននៃនិយ័តករគណនេយ្យនិងសវនកម្ម**

**១. នាយកដ្ឋានកិច្ចការទូទៅ**

ជាសេនាធិការឱ្យ ន.គ.ស. លើតួនាទី និងភារកិច្ចដូចខាងក្រោម៖

- **រដ្ឋបាល និងហិរញ្ញវត្ថុ៖** គ្រប់គ្រងការងាររដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក ធនធានមនុស្ស និងទ្រព្យសម្បត្តិរបស់រដ្ឋ ដោយនាយកដ្ឋានក៏ទទួលបន្ទុករៀបចំផែនការ និងថវិកាប្រចាំឆ្នាំផងដែរ។
- **បច្ចេកវិទ្យា និងទំនាក់ទំនង៖** គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ទំនាក់ទំនងជាមួយស្ថាប័នជាតិ អន្តរជាតិ និងវិស័យឯកជន ព្រមទាំងផ្សព្វផ្សាយព័ត៌មានជាសាធារណៈ។
- **សម្របសម្រួលទូទៅ៖** សម្របសម្រួល និងបូកសរុបផែនការសកម្មភាពរួមរបស់គ្រប់នាយកដ្ឋានក្នុងស្ថាប័ន។

**២. នាយកដ្ឋានបច្ចេកទេស**

ជាសេនាធិការឱ្យ ន.គ.ស. លើតួនាទី និងភារកិច្ចដូចខាងក្រោម៖

- **រៀបចំស្តង់ដា៖** សិក្សាស្រាវជ្រាវ និងរៀបចំ ស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម ក្រមសីលធម៌វិជ្ជាជីវៈ និងស្តង់ដាពាក់ព័ន្ធផ្សេងៗទៀត។
- **បកស្រាយ និងតាមដាន៖** ពន្យល់ និងបកស្រាយលើទិដ្ឋភាពបច្ចេកទេសនៃស្តង់ដាទាំងនោះ ព្រមទាំងពិនិត្យមើលការអនុវត្តជាក់ស្តែង និងកំណត់បញ្ហាប្រឈមដើម្បីស្នើសុំដំណោះស្រាយ។
- **កិច្ចសហប្រតិបត្តិការ៖** សហការជាមួយស្ថាប័នក្នុងតំបន់ និងអន្តរជាតិ ដើម្បីធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍន៍ស្តង់ដាឱ្យមានភាពទាន់សម័យ។

**៣. នាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម**

ជាសេនាធិការឱ្យ ន.គ.ស. លើតួនាទី និងភារកិច្ចដូចខាងក្រោម៖

- **ការផ្តល់អាជ្ញាបណ្ណ និងបទប្បញ្ញត្តិ៖** ពិនិត្យសំណើ និងផ្តល់អាជ្ញាបណ្ណដល់អ្នកប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម។ នាយកដ្ឋានក៏ទទួលខុសត្រូវក្នុងការរៀបចំ និងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណនេះផងដែរ។
- **ការត្រួតពិនិត្យ និងគ្រប់គ្រង៖** ត្រួតពិនិត្យគុណភាពសេវាគណនេយ្យនិងសវនកម្ម ព្រមទាំងគ្រប់គ្រងទិន្នន័យរបស់ក្រុមហ៊ុនដែលបានចុះបញ្ជី។ នាយកដ្ឋានក៏ចូលរួមអនុវត្តវិធានការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មផងដែរ។
- **ការអភិវឌ្ឍជំនាញ៖** រៀបចំ និងគ្រប់គ្រងកម្មវិធីសិក្សាសម្រាប់អភិវឌ្ឍន៍គណនេយ្យករជំនាញនៅកម្ពុជា។

**៤. នាយកដ្ឋានកិច្ចការគតិយុត្ត និងអនុលោមភាព**

ជាសេនាធិការឱ្យ ន.គ.ស. លើតួនាទី និងភារកិច្ចដូចខាងក្រោម៖

- **ការរៀបចំច្បាប់ និងបទប្បញ្ញត្តិ៖** ទទួលខុសត្រូវក្នុងការរៀបចំ និងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិចាំបាច់នានា ដើម្បីពង្រឹងការអនុវត្តច្បាប់។
- **ការត្រួតពិនិត្យ និងវាយតម្លៃ៖** ត្រួតពិនិត្យ និងវាយតម្លៃលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដើម្បីធានាថាពួកគេអនុលោមតាមច្បាប់ និងស្តង់ដាពាក់ព័ន្ធ។ នាយកដ្ឋានក៏ចូលរួមក្នុងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មផងដែរ។

– **ការអប់រំ និងផ្សព្វផ្សាយ៖** រៀបចំការបណ្តុះបណ្តាល និងផ្សព្វផ្សាយច្បាប់ បទប្បញ្ញត្តិ និងស្តង់ដាពាក់ព័ន្ធទៅកាន់សាធារណជន។

## ៣.២ គោលការណ៍សំខាន់ៗនៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២

### ៣.២.១ និយមន័យ

ដោយនៅក្នុងស្តង់ដានេះបានអោយនិយមន័យទៅលើសន្និធិដូចខាងក្រោម៖

**សន្និធិ** គឺជាទ្រព្យសកម្មដែលៈ

- ទុកសម្រាប់លក់នៅក្នុងសកម្មភាពអាជីវកម្ម
- ផលិតផលពាក់កណ្តាលសម្រេច
- ក្នុងទម្រង់ជាវត្ថុធាតុដើម ឬគ្រឿងផ្គត់ផ្គង់ដែលត្រូវបានប្រើប្រាស់ក្នុងចង្វាក់ផលិកម្ម ឬនៅក្នុងការផ្តល់សេវាកម្ម។

**តម្លៃសុទ្ធដែលគួរឱ្យទុកចិត្តបាន**គឺជាតម្លៃលក់ដែលបានប៉ាន់ស្មាននៅក្នុងដំណើរការជាធម្មតានៃអាជីវកម្មដកឱ្យថ្លៃដើមប៉ាន់ស្មានចុងក្រោយ និងថ្លៃដើមប៉ាន់ស្មានចាំបាច់នានាដើម្បីលក់។

**តម្លៃទីផ្សារ** គឺជាចំនួនទឹកប្រាក់ដែលទ្រព្យសកម្មមួយអាចដោះដូរជាមួយ បាន ឬបំណុលត្រូវបានទូទាត់សងជាមួយភាគីពាក់ព័ន្ធនៅក្នុងសកម្មភាព អាជីវកម្ម ។

### ៣.២.២ ការវាស់វែងថ្លៃដើមសន្និធិ

ការវាស់វែងនៃសារពើភ័ណ្ឌ សារពើភ័ណ្ឌគួរតែត្រូវបានវាស់នៅតម្លៃទាប និងតម្លៃសុទ្ធដែលអាចសម្រេចបាន។ ដោយការវាស់វែងនៃសារពើភ័ណ្ឌមានដូចខាងក្រោម៖

- **ថ្លៃដើមរបស់សន្និធិ៖** ថ្លៃដើមរបស់សន្និធិ ត្រូវមានសមាសធាតុនៃគ្រប់ថ្លៃដើមទិញទាំងអស់ ថ្លៃដើមបំលែង និងថ្លៃដើមដទៃទៀត ដែលបានកើតឡើងក្នុងការនាំ សន្និធិទៅដល់ទីកន្លែងរបស់វានិងតាមលក្ខខ័ណ្ឌសមប្រកប។
- **ថ្លៃដើមទិញ៖** រួមបញ្ចូលតម្លៃទិញ ពន្ធនាំចូល ការដឹកជញ្ជូន ថ្លៃរត់ការ និងថ្លៃដើមផ្សេងទៀតដែលទាក់ទងដោយផ្ទាល់នឹងការទិញផលិតផល ឬវត្ថុធាតុដើម។ ការបញ្ចុះតម្លៃពាណិជ្ជកម្ម និងប្រាក់បង្វិលសងត្រូវបានកាត់ចេញពីថ្លៃដើមទិញ។
- **ថ្លៃដើមបំលែង៖** រួមបញ្ចូលថ្លៃដើមពលកម្មផ្ទាល់ និងការធ្វើវិភាជចំណាយផលិតកម្មថេរ និងប្រែប្រួល។
- **ថ្លៃដើមដទៃទៀត៖** ជាថ្លៃដើមដែលកើតឡើងដើម្បីនាំសន្និធិទៅដល់ទីកន្លែង និងលក្ខខណ្ឌសមស្របរបស់វា (ឧទាហរណ៍ ថ្លៃតុបតែងផលិតផលសម្រាប់អតិថិជនពិសេស)

  ក. ចំនួនទឹកប្រាក់ថ្លៃដើមមិនធម្មតានៃសម្ភារៈដែលខូចខាត ពលកម្មនិងផលិតកម្មដទៃទៀត

  ខ. ថ្លៃដើមរក្សាទុក លើកលែងតែថ្លៃដើមនោះចាំបាច់នៅក្នុងដំណើរការផលិតកម្ម មុនដំណាក់កាលផលិតក្រោយៗទៀត

  គ. ចំណាយរដ្ឋបាលដែលមិនចូលរួមក្នុងការនាំសន្និធិទៅទីកន្លែងរក្សាទុកស្របតាមលក្ខខណ្ឌនៃការទុកដាក់សន្និធិ

  ឃ. ថ្លៃដើមលក់។

ស្តង់ដាគណនេយ្យអន្តរជាតិលេខ ២៣ ស្តីពីថ្លៃដើមកម្ចី បានកំណត់ អំពីកាលទេសៈមួយចំនួនដែលថ្លៃដើមកម្ចីត្រូវបានបញ្ចូលនៅក្នុងថ្លៃដើមសន្និធិ ។

អង្គភាពមួយ អាចទិញសន្និធិតាមលក្ខខណ្ឌពន្យានៃការបង់ប្រាក់ នៅពេលដែលកិច្ចសន្យាមានធាតុហិរញ្ញវត្ថុ ដូចជាភាពខុសគ្នារវាងថ្លៃទិញ តាមលក្ខខណ្ឌឥណទានធម្មតាជាមួយនឹងចំនួនទឹកប្រាក់ ដែលបានបង់ធាតុនោះ ត្រូវបានទទួលស្គាល់ជាចំណាយលើការប្រាក់ក្នុងការិយបរិច្ឆេទ ធ្វើហិរញ្ញប្បទាន។

➢ **ថ្លៃដើមរបស់សន្និធិរបស់អ្នកផ្តល់សេវាកម្ម**

អ្នកផ្តល់សេវាកម្មវាស់វែងសន្និធិតាមថ្លៃដើមផលិតសេវា រួមមានថ្លៃពលកម្មផ្ទាល់ បុគ្គលិកគ្រប់គ្រងផ្ទាល់ និងចំណាយពាក់ព័ន្ធផ្សេងទៀត ថ្លៃដើមពាក់ព័ន្ធនឹងការលក់ ឬរដ្ឋបាលទូទៅមិនត្រូវបានរាប់បញ្ចូលទេ។

➢ **ថ្លៃដើមនៃកសិផលដែលបានប្រមូលពីទ្រព្យសកម្មជីវសាស្ត្រ**

កសិផលដែលប្រមូលបានពីទ្រព្យសកម្មជីវសាស្ត្រ ត្រូវបានវាស់វែងតាមតម្លៃទីផ្សារដែលទទួលស្គាល់ដំបូងដកថ្លៃដើមលក់ ស្របតាមស្តង់ដាគណនេយ្យអន្តរជាតិលេខ ២៣ ស្តីពីកសិកម្ម។

➢ **បច្ចេកទេសសម្រាប់ប្រើក្នុងការវាស់វែងថ្លៃដើម**

បច្ចេកទេសសម្រាប់វាស់វែងថ្លៃដើមសន្និធិ ដូចជាវិធីសាស្ត្រថ្លៃដើមស្តង់ដា ឬវិធីសាស្ត្រលក់រាយ អាចត្រូវបានប្រើប្រាស់យ៉ាងសមរម្យ ប្រសិនបើលទ្ធផលប្រហាក់ប្រហែលថ្លៃដើម។ ថ្លៃដើមស្តង់ដា គិតអំពីកម្រិតធម្មតានៃសម្ភារៈ និងឧបករណ៍ ពលកម្ម ប្រសិទ្ធភាព និងការប្រើប្រាស់សមត្ថភាព។ ប្រសិនបើមានការចាំបាច់ជាធម្មតាគេពិនិត្យឡើងវិញ និងកែសម្រួលឡើងវិញតាមលក្ខខណ្ឌជាក់ស្តែងដែលបានកើតឡើង។

វិធីសាស្ត្រលក់រាយ តែងតែត្រូវបានប្រើប្រាស់ក្នុងឧស្សាហកម្មលក់រាយ សម្រាប់វាស់វែងសន្និធិ លើធាតុមួយចំនួនដែលមានការប្រែប្រួលលឿននៅក្នុងគម្លាតប្រហាក់ប្រហែលដែលការនេះគេមិនអាចប្រើវិធីសាស្ត្រថ្លៃដើមដទៃទៀតបាន។ ថ្លៃដើមសន្និធិ ត្រូវបានកំណត់ដោយការកាត់បន្ថយ តម្លៃលក់របស់សន្និធិតាមគម្លាតសរុបសមាមាត្រដែលសមហេតុផល។ ចំនួនភាគរយដែលប្រើប្រាស់ ត្រូវពិចារណាអំពីសន្និធិដែលបានកំណត់ តម្លៃទាបក្រោមថ្លៃលក់ដំបូងរបស់វាចំនួនភាគរយជាមធ្យមសម្រាប់ ការលក់តាមផ្នែកតែងតែត្រូវបានប្រើប្រាស់ ។

**៣.២.៣ វិធីសាស្ត្រគណនាថ្លៃដើមសន្និធិ**

ថ្លៃដើមសន្និធិត្រូវបានបំបែកដោយឡែកតាមគម្រោងពិសេសនានា ត្រូវបានធ្វើឡើងដោយប្រើប្រាស់ការកំណត់ជាពិសេសលើថ្លៃដើមនីមួយៗរបស់វា។ វិធីសាស្ត្រនេះមានន័យថា ថ្លៃដើមជាក់លាក់នីមួយៗត្រូវបានកំណត់ទៅលើធាតុសន្និធិជាក់លាក់មួយវាងាយស្រួលសម្រាប់ធាតុដែលបំបែកតាមគម្រោងពិសេស ទោះបីជាត្រូវបានទិញ ឬផលិតក៏ដោយ។ ចំណុចសំខាន់៖ វិធីសាស្ត្រនេះមិនស័ក្តិសមទេ ប្រសិនបើមានធាតុសន្និធិជាច្រើនដែលមិនអាចដោះដូរគ្នាបានធម្មតា ព្រោះវាអាចបណ្តាលឱ្យមានឥទ្ធិពលទៅលើចំណេញខាតតាមរយៈការជ្រើសរើសធាតុ។

❖ វិធីសាស្ត្រកំណត់ថ្លៃដើមផ្សេងទៀត

លើកលែងតែធាតុសន្និធិដែលកំណត់ដោយថ្លៃដើមជាពិសេស ថ្លៃដើមសន្និធិត្រូវបានកំណត់ដោយប្រើប្រាស់វិធីសាស្ត្រ ចូលមុនចេញមុន (FIFO) ឬ រូបមន្តថ្លៃដើមមធ្យម (Cost Average)។

-រូបមន្តចូលមុនចេញមុន (FIFO): វិធីសាស្ត្រនេះសន្មត់ថាជាតុសន្និធិដែលបានទិញ ឬផលិតមុន ត្រូវបានលក់ចេញមុន។ ដូច្នេះ ជាតុដែលនៅសេសសល់ក្នុងសន្និធិនៅចុងអាណត្តិ គឺជាជាតុដែលបានទិញ ឬផលិតថ្មីៗបំផុត។

-រូបមន្តថ្លៃដើមមធ្យម (Cost Average): ថ្លៃដើមនៃជាតុនីមួយៗត្រូវបានកំណត់ដោយថ្លៃដើមមធ្យមទម្ងន់នៃជាតុស្រដៀងគ្នានៅដើមអាណត្តិ បូករួមនឹងថ្លៃដើមនៃជាតុស្រដៀងគ្នាដែលបានទិញ ឬផលិតក្នុងអំឡុងអាណត្តិ មធ្យមភាគនេះអាចត្រូវបានគណនាតាមដំណាក់កាល អាស្រ័យលើស្ថានភាពរបស់ក្រុមហ៊ុន។

**៣.២.៤ តម្លៃសុទ្ធគួរឱ្យទុកចិត្តបាន**

-ថ្លៃដើមនៃសន្និធិអាចមិនទទួលបានមកវិញ ប្រសិនបើសន្និធិទាំងនោះ ត្រូវបានខូចខាត វាក្លាយជាឥតបានការទាំងស្រុងឬក៏មួយផ្នែក ឬប្រសិនបើថ្លៃលក់របស់វាត្រូវបានបដិសេធ និងប្រសិនបើថ្លៃដើមប៉ាន់ស្មានពេញលេញ ឬថ្លៃដើមប៉ាន់ស្មានដែលបានកើតឡើងសម្រាប់ការលក់មានការប្រែប្រួល ការអនុវត្តការកត់ត្រាសន្និធិចូលទាបជាងថ្លៃដើម តម្លៃសុទ្ធដែលគួរឱ្យទុកចិត្តបានមានសង្គតិភាពជាមួយទស្សននៃទ្រព្យសកម្មត្រូវបានរក្សាទុកលើស ពីចំនួនដែលគេរំពឹងទុកថានឹងទទួលបានមកវិញពីការលក់ ឬការប្រើប្រាស់វា។

-ការកត់ត្រាចូលនូវតម្លៃសុទ្ធដែលគួរឱ្យទុកចិត្តបានតាមជាតុនីមួយៗ ក្នុងករណីខ្លះ វាអាចសមហេតុផលក្នុងការវាយតម្លៃជាក្រុមសម្រាប់ជាតុសន្និធិដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ឬទាក់ទងគ្នា ដូចជាជាតុដែលស្ថិតក្នុង បណ្តាញផលិតផលដូចគ្នា មានគោលបំណង ឬការប្រើប្រាស់ស្រដៀងគ្នា ត្រូវបាន ផលិត និងដាក់លក់នៅក្នុងតំបន់ភូមិសាស្ត្រដូចគ្នា ហើយមិនអាចវាយតម្លៃដាច់ដោយឡែកបាន។ វាជាការមិនត្រឹមត្រូវទេក្នុងការវាយតម្លៃសន្និធិដោយផ្អែកលើមូលដ្ឋាននៃការចាត់ថ្នាក់ទូទៅ ដូចជា "ផលិតផលសម្រេច" ឬ " សន្និធិទាំងអស់នៅក្នុងផ្នែកប្រតិបត្តិការដាច់ដោយឡែក"។ ចំពោះអ្នកផ្តល់សេវា ថ្លៃដើមត្រូវបានកំណត់សម្រាប់ សេវាកម្មនីមួយៗ ដែលគិតថ្លៃដាច់ដោយឡែក ដូច្នេះសេវាកម្មនីមួយៗត្រូវចាត់ទុកជាជាតុដាច់ដោយឡែក។ ការប៉ាន់ស្មានលើតម្លៃសុទ្ធដែលគួរឱ្យទុកចិត្ត ត្រូវបានផ្អែកលើមូលដ្ឋានភស្តុតាងដែលគួរឱ្យទុកចិត្តបានបំផុតដែលអាចរកបាននាពេលធ្វើការប៉ាន់ស្មានលើចំនួនទឹកប្រាក់ ដែលសន្និធិត្រូវបានរំពឹងទុកថានឹងទទួលបាន។ ការប៉ាន់ស្មានទាំងនេះក៏ត្រូវគិតគូរពី ការប្រែប្រួលតម្លៃ ឬថ្លៃដើម ដែលទាក់ទងដោយផ្ទាល់ទៅនឹងព្រឹត្តិការណ៍ដែលកើតឡើង ក្រោយកាលបរិច្ឆេទរបាយការណ៍ ប៉ុន្តែដែលបញ្ជាក់ពីលក្ខខណ្ឌដែលមាននៅចុងកាលបរិច្ឆេទរបាយការណ៍នោះ។

-ការប៉ាន់ស្មានលើតម្លៃសុទ្ធដែលគួរឱ្យទុកចិត្ត ក៏ត្រូវយកមកពិចារណាផង ដែរអំពីគោលបំណងនៃការរក្សាទុកសន្និធិ។ ឧទាហរណ៍ សន្និធិសម្រាប់បំពេញកិច្ចសន្យា សម្រាប់បរិមាណសន្និធិដែលត្រូវបានរក្សាទុកដើម្បីបំពេញ កិច្ចសន្យាលក់ ឬ កិច្ចសន្យាផ្តល់សេវាកម្ម ដែលមានស្រាប់តម្លៃសុទ្ធដែលគួរឱ្យទុកចិត្តត្រូវតែផ្អែកលើតម្លៃដែលបានព្រមព្រៀងក្នុងកិច្ចសន្យា នោះ។ សន្និធិលើសពីកិច្ចសន្យា ប្រសិនបើបរិមាណសន្និធិដែលមាន ច្រើនជាង បរិមាណដែលបានចែងក្នុងកិច្ចសន្យាលក់តម្លៃសុទ្ធដែលគួរឱ្យទុកចិត្តសម្រាប់បរិមាណដែលលើសនោះ ត្រូវតែផ្អែកលើ ថ្លៃលក់ទូទៅ នៅក្នុងទីផ្សារសំវិធានធនបែបនេះ ត្រូវបានដោះស្រាយដោយស្តង់ដា គណនេយ្យអន្តរជាតិលេខ ៣៧ ស្តីពី សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ។

-សម្ភារៈ ឬគ្រឿងផ្គត់ផ្គង់ដទៃទៀត ដែលទុកសម្រាប់ប្រើនៅក្នុងការផលិតសន្និធិមិនត្រូវបានកត់ត្រាចូលក្រោមថ្លៃដើម ប្រសិនបើផលិតផលសម្រេចដែលគេបានលាយបញ្ចូលគ្នា ត្រូវបានរំពឹងថាលក់តាម ឬលើស

ថ្លៃដើម។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលការធ្លាក់ចុះនូវថ្លៃនៃសម្ភារៈបង្ហាញថាថ្លៃដើមរបស់ផលិតផលសម្រេចលើសពីថ្លៃដើមសុទ្ធដែលគួរឱ្យទុកចិត្តបាន នោះសម្ភារៈទាំងនោះត្រូវកត់ត្រានូវ ថ្លៃដើមសុទ្ធដែលគួរឱ្យទុកចិត្តបាន។ ក្នុងកាលទេសៈបែបនេះ ថ្លៃដើមជំនួសរបស់សម្ភារៈគឺជាខ្នាត ដែលអាចធ្វើបានល្អបំផុតនៃថ្លៃដើមសុទ្ធដែលគួរឱ្យទុកចិត្តបានរបស់សម្ភារៈនោះ។

-ការវាយតម្លៃជាថ្មីត្រូវបានធ្វើឡើងលើតម្លៃសុទ្ធដែលគួរឱ្យទុកចិត្តនៅក្នុង ការិយបរិច្ឆេទបន្តបន្ទាប់ នៅពេលដែលកាលទេសៈដែលពីមុនមក ធ្វើឱ្យសន្និធិត្រូវបានកត់ត្រា ក្រោមថ្លៃដើម ដែលមានក្នុងរយៈពេលមិនយូរ ឬនៅពេលដែលមានភស្តុតាងច្បាស់លាស់បង្ហាញអំពីការកើនឡើងនូវ តម្លៃសុទ្ធដែលគួរឱ្យទុកចិត្ត ដោយសារតែការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ច ចំនួនទឹកប្រាក់ដែលបានកត់ត្រាត្រូវបានធ្វើបញ្រ្ជាសមកវិញ (ដូចជាការកត់ត្រាបញ្រ្ជាស ត្រូវបានដាក់កំហិតចំពោះចំនួនទឹកប្រាក់ដែលបានកត់ត្រាពីដើមដំបូង) ដូចនេះតម្លៃពិតគណនេយ្យ ទាបជាងថ្លៃដើម និងទាបជាងតម្លៃសុទ្ធដែលគួរឱ្យទុកចិត្ត។ ឧទាហរណ៍ ដោយសារតែថ្លៃលក់របស់វាបានកើនឡើងករណីនេះកើតមាននៅពេលដែលជាតុមួយ នៃសន្និធិដែលបានកត់ត្រាតាមតម្លៃសុទ្ធដែលគួរឱ្យទុកចិត្តនៅតែមានក្នុងដៃនាការិយបរិច្ឆេទបន្តបន្ទាប់ ហើយថ្លៃលក់របស់វាបានកើនឡើង។

**៣.២.៥ ការទទួលស្គាល់ជាចំណូល**

-នៅពេលដែលសន្និធិត្រូវបានលក់ចេញនូវតម្លៃពិតគណនេយ្យនៃសន្និធិ ដែលរួមមានការបាត់បង់នៃសន្និធិត្រូវបានទទួលស្គាល់ថាជាចំណាយមួយក្នុងការិយបរិច្ឆេទហើយចំណូលពាក់ព័ន្ធត្រូវបានទទួលស្គាល់បរិមាណនៃសន្និធិដែលបានកត់ត្រាតាមតម្លៃសុទ្ធដែលគួរឱ្យទុកចិត្ត។ ចំនួនទឹកប្រាក់នៃការកត់ត្រាបញ្រ្ជាសរបស់សន្និធិដែលកើតពីការកើនឡើងនៃតម្លៃសុទ្ធដែលគួរឱ្យទុកចិត្តត្រូវទទួលស្គាល់ថាជាការកាត់ចេញពីចំនួនទឹកប្រាក់នៃសន្និធិដែលបានទទួលស្គាល់ថាជាចំណាយនាការិយបរិច្ឆេទផងដែរ។

-សន្និធិខ្លះ អាចត្រូវបានបញ្ចូលក្នុងគណនីទ្រព្យសកម្មដទៃទៀត ឧទាហរណ៍សន្និធិដែលបានប្រើជាសមាសជាតុមួយនៃទ្រព្យសកម្មដែលបានបង្កើតឡើងដោយខ្លួនឯង រោងចក្រ ឬសម្ភារៈ សន្និធិនានាដែលបានបញ្ចូល ក្នុងទ្រព្យសកម្មដទៃទៀតតាមមធ្យោបាយនេះត្រូវបានទទួលស្គាល់ថាជាចំណាយមួយក្នុងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មនោះ។

**៣.២.៦ ការលាតត្រដាងពត៌មាន**

របាយការណ៍ហិរញ្ញវត្ថុ ត្រូវលាតត្រដាងព័ត៌មាន៖

- គោលនយោបាយគណនេយ្យដែលបានអនុម័តដើម្បីវាស់វែងសន្និធិ រួមទាំងរូបមន្តថ្លៃដើមដែលបានប្រើប្រាស់
- តម្លៃពិតគណនេយ្យសរុបរបស់សន្និធិ និងតម្លៃពិតគណនេយ្យ ក្នុងការធ្វើចំណាត់ថ្នាក់ សមស្របជាមួយអង្គភាព
- តម្លៃពិតគណនេយ្យរបស់សន្និធិដែលបានធ្វើឡើងតាមតម្លៃទីផ្សារដកឱ្យថ្លៃដើមលក់
- បរិមាណនៃសន្និធិដែលត្រូវបានទទួលស្គាល់ថាជាចំណាយនៅក្នុងការិយបរិច្ឆេទ
- បរិមាណនៃការកត់ត្រាសន្និធិដែលបានទទួលស្គាល់ថាជាចំណាយ ក្នុងការិយបរិច្ឆេទ
- បរិមាណនៃការកត់ត្រាបញ្រ្ជាសពីកំណត់ត្រាមុនដែលត្រូវបាន ទទួលស្គាល់ថាជាការកាត់ចេញពីបរិមាណសន្និធិ ដែលបានទទួល ស្គាល់ថាជាចំណាយក្នុងការិយបរិច្ឆេទ
- កាលៈទេសៈ ឬព្រឹត្តិការណ៍ដែលនាំឱ្យមានការកត់ត្រាបញ្រ្ជាស ពីកំណត់ត្រាសន្និធិ និង តម្លៃពិតគណនេយ្យរបស់សន្និធិដែលជាប់កិច្ចសន្យាជាការធានាចំពោះបំណុល

- ព័ត៌មានលម្អិតអំពីតម្លៃពិតគណនេយ្យនៃប្រភេទសន្និធិផ្សេងៗគ្នា និងការប្រែប្រួលរបស់វាគឺមានសារៈសំខាន់ណាស់សម្រាប់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ។
- ចំនួនសន្និធិដែលត្រូវបានទទួលស្គាល់ថាជាចំណាយមួយនៅក្នុងការិយបរិច្ឆេទដែលតែងតែសំដៅដល់ថ្លៃដើមលក់រួមមានថ្លៃដើមដែលពីមុនមកត្រូវបានបញ្ចូលនៅក្នុងការវាស់វែងសន្និធិដែលឥឡូវបានលក់ ហើយមិនបានបញ្ចូលជាចំណាយក្នុងផលិតកម្មនិងមិនបានបញ្ចូលក្នុងចំនួនថ្លៃដើមផលិតកម្មមិនធម្មតារបស់សន្និធិ។ ស្ថានភាពរបស់អង្គភាពអាចអនុញ្ញាតឱ្យមានការដាក់បញ្ចូលនូវចំនួនទឹកប្រាក់ដទៃទៀតដូចជាថ្លៃដើមចែកចាយ។
- អង្គភាពខ្លះ អនុម័តទម្រង់សម្រាប់ចំណេញខាតដែលបង្ហាញលទ្ធផលជាចំនួនទឹកប្រាក់ដែលត្រូវលាតត្រដាងព័ត៌មានក្រៅពីថ្លៃដើមសន្និធិដែលត្រូវបានទទួលស្គាល់ថាជាចំណាយនៅក្នុងការិយបរិច្ឆេទ។ តាមទម្រង់នេះអង្គភាពបង្ហាញនូវការវិភាគលើចំណាយដោយប្រើចំណាត់ថ្នាក់មួយផ្អែកលើមូលដ្ឋាននៃប្រភេទនៃចំណាយ។ ក្នុងករណីនេះអង្គភាពលាតត្រដាងព័ត៌មានអំពីថ្លៃដើមដែលបានទទួលស្គាល់ថាជាចំណាយសម្រាប់វត្ថុធាតុដើម និងគ្រឿងប្រើប្រាស់ ថ្លៃដើមពលកម្ម និងថ្លៃដើមដទៃទៀត ជាមួយ នឹងចំនួនទឹកប្រាក់នៃការប្រែប្រួលសរុបលើសន្និធិសម្រាប់ការិយបរិច្ឆេទ។

## ៣.៣ លក្ខខណ្ឌនៃសន្និធិត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុ

សារពើភ័ណ្ឌត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ នៅពេលដែលពួកគេបំពេញតាមលក្ខណៈវិនិច្ឆ័យជាក់លាក់ទាក់ទងនឹងកម្មសិទ្ធិ អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត និងការវាស់វែងដែលអាចទុកចិត្តបាន។ សារពើភ័ណ្ឌ ត្រូវបានរាប់បញ្ចូលទាំងវត្ថុដែលរក្សាទុកសម្រាប់លក់ ក្នុងដំណើរការផលិតសម្រាប់លក់ ឬសម្ភារៈដែលត្រូវប្រើប្រាស់ ជាទូទៅគឺជាទ្រព្យសកម្មបច្ចុប្បន្ននៅលើតារាងតុល្យការ តម្លៃនៃសារពើភ័ណ្ឌត្រូវបានផ្ទេរទៅតម្លៃនៃទំនិញដែលបានលក់ (COGS) នៅពេលដែលសារពើភ័ណ្ឌត្រូវបានលក់។ លក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ជាទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដូចខាងក្រោម៖

**១. ភាពជាម្ចាស់ និងការគ្រប់គ្រង៖** ក្រុមហ៊ុនត្រូវតែមានកម្មសិទ្ធិ ឬគ្រប់គ្រងលើសារពើភ័ណ្ឌ មានន័យថា វាមានលទ្ធភាពប្រើប្រាស់ ឬលក់ទំនិញ។

**២. អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត៖** វាត្រូវតែជាអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលទាក់ទងនឹងសារពើភ័ណ្ឌនឹងការផ្តល់ប្រាក់ចំណេញទៅក្រុមហ៊ុន។

**៣. ការវាស់វែងដែលអាចទុកចិត្តបាន៖** ថ្លៃដើម ឬតម្លៃផ្សេងទៀតនៃសារពើភ័ណ្ឌអាចត្រូវបានវាស់វែងដោយភាពជឿជាក់។

**៤. ប្រភេទសារពើភ័ណ្ឌ និងការវាស់វែង៖** សារពើភ័ណ្ឌអាចរួមបញ្ចូលវត្ថុធាតុដើម ការងារដែលកំពុងដំណើរការ និងទំនិញសម្រេច។ សារពើភ័ណ្ឌត្រូវបានវាស់ជាទូទៅនៅតម្លៃទាប និងតម្លៃសុទ្ធគួរទុកចិត្តបានដោយការចំណាយរួមមានចំណាយទាំងអស់នៃការទិញ ការចំណាយលើការបំប្លែង និងការចំណាយផ្សេងទៀតដើម្បីនាំយកសារពើភ័ណ្ឌទៅកាន់ទីតាំង និងលក្ខខណ្ឌបច្ចុប្បន្នរបស់វា។ តម្លៃសុទ្ធគួរទុកចិត្តបានគឺជាតម្លៃលក់ប៉ាន់ស្មានដែលចំណាយតិចក្នុងការបញ្ចប់ និងលក់សារពើភ័ណ្ឌ។

**៥. បទបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ៖** ជាធម្មតាសារពើភ័ណ្ឌត្រូវបានបង្ហាញជាទ្រព្យសកម្មនៅលើតារាងតុល្យការ នៅពេលដែលសារពើភ័ណ្ឌត្រូវបានលក់ ការចំណាយរបស់វាត្រូវបានផ្ទេរទៅតម្លៃនៃទំនិញដែលបានលក់ (COGS) នៅលើរបាយការណ៍ប្រាក់ចំណូល។ ការចំណាយមួយចំនួនដូចជា កាកសំណល់

មិនប្រក្រតី ការចំណាយលើការផ្ទុកមិនទាក់ទងនឹងការផលិត ឬការចំណាយលើរដ្ឋបាលដែលមិនរួមចំណែកដល់ស្ថានភាពបច្ចុប្បន្នរបស់សារពើភ័ណ្ឌ មិនត្រូវបានរាប់បញ្ចូលក្នុងការចំណាយលើសារពើភ័ណ្ឌ និងត្រូវបានចំណាយក្នុងអំឡុងពេលដែលពួកគេត្រូវបានកើតឡើង។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ក្រោយពីបានសិក្សាស្រាវជ្រាវ ទៅលើប្រធានបទស្តីពី សារៈសំខាន់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២ បានស្តែងអោយឃើញចំណុចខ្លាំង ក៏ដូចជាសក្តានុពល និងចំណុចខ្សោយរបស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២ជាច្រើនដែលគួរអោយកត់សម្គាល់ ក្នុងនោះរួមមានដូចខាងក្រោម៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

- បង្កើនតម្លាភាព និងភាពអាចប្រៀបធៀបបាន៖ ស្តង់ដាគណនេយ្យអន្តរជាតិ២ស្តីពីសន្និធិផ្តល់នូវគោលការណ៍រួមសម្រាប់ក្រុមហ៊ុននានាក្នុងការវាស់វែង និងរាយការណ៍សន្និធិ ផ្តល់ភាពងាយស្រួលឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ (ដូចជានិយោគិន ម្ចាស់បំណុលជាដើម) ក្នុងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ អាចប្រៀបធៀបព័ត៌មាន រវាងក្រុមហ៊ុនផ្សេងៗគ្នា ឬតាមរយៈពេលផ្សេងៗគ្នាយ៉ាងងាយស្រួល។ ការកំណត់និយមន័យច្បាស់លាស់នៃសន្និធិ ថ្លៃដើម និងវិធីសាស្ត្រវាស់វែង ធ្វើឱ្យរបាយការណ៍ហិរញ្ញវត្ថុ មានតម្លាភាព កាន់តែខ្ពស់។
- ការទទួលស្គាល់ថ្លៃដើមដ៏ទូលំទូលាយ៖ ស្តង់ដានេះបានកំណត់យ៉ាងច្បាស់នូវសមាសធាតុទាំងអស់ដែលត្រូវរាប់បញ្ចូលក្នុង ថ្លៃដើមសន្និធិ រួមមានថ្លៃទិញ ថ្លៃបំប្លែង និងថ្លៃចំណាយដទៃទៀតដែលចាំបាច់ដើម្បីឱ្យសន្និធិស្ថិតនៅទីតាំង និងស្ថានភាពបច្ចុប្បន្នរបស់វា។ ការរួមបញ្ចូលថ្លៃដើមពាក់ព័ន្ធទាំងអស់ជួយឱ្យក្រុមហ៊ុនរាយការណ៍ពី ថ្លៃដើមពិតប្រាកដ របស់សន្និធិបានកាន់តែត្រឹមត្រូវ។
- គោលការណ៍ "ថ្លៃដើមទាប ឬតម្លៃសុទ្ធគួរអោយទុកចិត្តបាន"៖ គោលការណ៍នេះ (Lower of Cost and Net Realizable Value) គឺជាចំណុចខ្លាំងមួយដែលអនុញ្ញាតឱ្យក្រុមហ៊ុនកត់ត្រាសន្និធិក្នុងតម្លៃដែល មិនខ្ពស់ជាងតម្លៃពិត ដែលអាចទទួលបានពីការលក់វាឡើយ។ វាជួយឱ្យរបាយការណ៍ហិរញ្ញវត្ថុឆ្លុះបញ្ចាំងពីភាពប្រុងប្រយ័ត្ន (Prudence) និងធានាថាទ្រព្យសកម្មមិនត្រូវបានវាយតម្លៃខ្ពស់ពេក នៅពេលដែលតម្លៃទីផ្សាររបស់វាធ្លាក់ចុះ។
- ការបកស្រាយលម្អិតសម្រាប់ការអនុវត្តជាក់ស្តែង៖ ស្តង់ដានេះបានរៀបរាប់ពី វិធីសាស្ត្រគណនាថ្លៃដើម (ដូចជា FIFO និង Cost Average) និងបច្ចេកទេសវាស់វែងដែលផ្តល់ភាពបត់បែនដល់ក្រុមហ៊ុនក្នុងការជ្រើសរើសវិធីសាស្ត្រដែលសមស្របតាមលក្ខណៈអាជីវកម្មរបស់ខ្លួន។ វាថែមទាំងបានលើកឡើងពី ករណីពិសេស មួយចំនួនដូចជា សន្និធិរបស់ក្រុមហ៊ុនផ្តល់សេវាកម្ម កសិផល និងទំនាក់ទំនងជាមួយស្តង់ដាផ្សេងៗ (ដូចជា IAS 23 - Borrowing Costs) ដែលបង្ហាញពីភាពស៊ីជម្រៅនៃការណែនាំ។
- តម្រូវការលាតត្រដាងព័ត៌មានលម្អិត៖ ស្តង់ដានេះតម្រូវឱ្យក្រុមហ៊ុនលាតត្រដាងព័ត៌មានសំខាន់ៗជាច្រើនអំពីសន្និធិរបស់ខ្លួន (ដូចជាគោលនយោបាយគណនេយ្យ ថ្លៃដើមសរុប ប្រភេទសន្និធិ ការកត់ត្រាចុះតម្លៃ)។ ការលាតត្រដាងនេះជួយឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ យល់កាន់តែច្បាស់ អំពីរបៀបដែលសន្និធិត្រូវបានគ្រប់គ្រង និងវាស់វែង។

## ៤.២ ការវិភាគលើចំណុចខ្សោយ

- ភាពបត់បែននៃវិធីសាស្ត្រគណនាថ្លៃដើមអាចកាត់បន្ថយភាពប្រៀបធៀបបាន៖ ទោះបីជាស្តង់ដានេះ អនុញ្ញាតឱ្យប្រើ FIFO (ចូលមុនចេញមុន) និង Cost Average (ថ្លៃដើមមធ្យម) ក៏ដោយ ការអនុញ្ញាត នេះអាចនាំឱ្យមាន ភាពខុសគ្នាក្នុងការរាយការណ៍ចំណេញ រវាងក្រុមហ៊ុនដែលប្រើវិធីសាស្ត្រផ្សេងគ្នា ជាពិសេសនៅពេលដែលតម្លៃទំនិញមានការប្រែប្រួលខ្លាំងនេះអាចធ្វើឱ្យភាពប្រៀបធៀបគ្នានៅតែមាន កម្រិតខ្លះ។
- ភាពស្មុគស្មាញក្នុងការកំណត់ថ្លៃដើម និងតម្លៃសុទ្ធគួរអោយទុកចិត្តបាន៖ ការកំណត់ ថ្លៃដើមសន្និធិ អាចមានភាពស្មុគស្មាញ ជាពិសេសសម្រាប់ក្រុមហ៊ុនផលិតកម្មដែលមានថ្លៃចំណាយច្រើនប្រភេទ (ផ្ទាល់ ប្រយោល ថេរ ប្រែប្រួល)។ ការប៉ាន់ស្មាន តម្លៃសុទ្ធគួរអោយទុកចិត្តបានក៏ទាមទារការវិនិច្ឆ័យ និងការប៉ាន់ស្មានច្រើនដែលអាចមានភាពមិនច្បាស់លាស់ និងអាចរងឥទ្ធិពលពីការលំអៀងរបស់អ្នកគ្រប់គ្រង។
- ការចំណាយលើការអនុវត្ត៖ ការអនុវត្តតាមតម្រូវការលម្អិតរបស់ស្តង់ដានេះ (ដូចជាការតាមដានថ្លៃដើម ការវាយតម្លៃ តម្លៃសុទ្ធគួរអោយទុកចិត្តបានជាប្រចាំ ការលាតត្រដាងព័ត៌មាន) អាចទាមទារ ប្រព័ន្ធគណនេយ្យដ៏រឹងមាំ និង ធនធានច្រើន ជាពិសេសសម្រាប់អាជីវកម្មខ្នាតតូច និងមធ្យម។

# ជំពូកទី ៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវលើស្ថានភាពទូទៅរបស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២និងបានធ្វើការសិក្សានានា តាមរយៈការស្រាវជ្រាវបែបបច្ចេកវិទ្យាកន្លងមកនិងពិនិត្យតាមការចងក្រងឯកសារក្នុងបណ្ណាល័យផ្សេងៗឱ្យបានឃើញថា ៖

តាមការសិក្សាស្រាវជ្រាវលើស្ថានភាពទូទៅរបស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២បានបង្ហាញអោយឃើញថា មានកំណើននៃការប្រើប្រាស់ទៅតាមស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា២ ពិតជាមានប្រសិទ្ធភាពល្អប្រសើរដោយសង្កេតឃើញថាក្នុងប្រទេសកម្ពុជាយើង ក្រុមហ៊ុន ស្ថាប័នធំៗជាច្រើន កំពុងតែប្រើប្រាស់និង ទទួលបានលទ្ធផលល្អ ក៏ដូចជា អាចគ្រប់គ្រង ប្រភេទទំនិញនិង ក៏ដូចជាការកត់ត្រា ផ្សេងៗ ដែលទាក់ទងទៅនឹងស្តុកទំនិញ ឬការផ្តល់សេវាជាច្រើនទៀត។ ការទទួលស្គាល់ជាការចំណាយ រួមទាំងការសរសេរចុះទៅតម្លៃសុទ្ធដែលអាចសម្រេចបាន។ ការណែនាំអំពីរូបមន្តចំណាយដែលត្រូវបានប្រើដើម្បីចាត់ចែងការចំណាយទៅលើសារពើភ័ណ្ឌ។ ការងារដែលកំពុងដំណើរការដែលកើតឡើងក្រោមកិច្ចសន្យាសាងសង់ រួមទាំងពាក់ព័ន្ធផ្ទាល់កិច្ចសន្យាសេវាកម្ម ឧបករណ៍ហិរញ្ញវត្ថុសារពើភ័ណ្ឌរបស់អ្នកផលិតនៃសត្វពាហនៈផលិតផលកសិកម្ម ព្រៃឈើ និងរ៉ែជាដើម។ ក្នុងវិសាលភាពដែលពួកគេត្រូវបានវាស់នៅតម្លៃសុទ្ធដែលអាចសម្រេចបានស្របតាមការអនុវត្តដែលបានបង្កើតឡើងយ៉ាងល្អនៅក្នុងឧស្សាហកម្មមួយចំនួន។ គោលការណ៍សំខាន់ៗនៃការគ្រប់គ្រងសន្និធិរបស់ស្តង់គណនេយ្យអន្តរជាតិនៃកម្ពុជា២។ ការវាស់វែងថ្លៃដើមសន្និធិគួរតែត្រូវបានវាស់នៅតម្លៃទាប និងតម្លៃសុទ្ធដែលអាចទុកចិត្តបាន ដោយការវាស់វែងនៃសារពើភ័ណ្ឌ ថ្លៃដើមរបស់សន្និធិ ថ្លៃដើមទិញ ថ្លៃដើមបំលែង ដំណើរការផលិតកម្ម អាចនាំឱ្យមានផលិតផលដែលត្រូវផលិតក្នុងពេលតែមួយដែលលើសពីមួយ។ ឧទាហរណ៍ដូចជាករណីនៅពេលដែលផលិតផល រណបត្រូវបានផលិតឡើង ឬនៅពេលដែលមានផលិតផលចម្បង និង នៅពេលដែលថ្លៃដើមបំលែងនៃផលិតផលនីមួយៗ មិនអនុផលអាចត្រូវបានកំណត់ដាច់ដោយឡែកពីគ្នាបាន ថ្លៃដើមទាំងនោះ ត្រូវបាន ផ្តល់រវាង ផលិតផលនានាដោយឈរលើមូលដ្ឋានសមហេតុផលនិងមានសង្គតិភាព។ ឧទាហរណ៍ ការផ្តល់នូវថ្លៃដើម អាចផ្អែកលើមូលដ្ឋាននៃតម្លៃ លក់ពាក់ព័ន្ធ នៃផលិតផលនីមួយៗ ទាំងនៅក្នុងដំណាក់កាលចង្វាក់ផលិតកម្មដែលផលិតផល អាចកំណត់ដាច់ដោយឡែកពីគ្នា និងទាំងនាពេលបញ្ចប់ការផលិត។ យោងលើធម្មជាតិនៃអនុផលភាគច្រើនវាមានលក្ខណៈមិនសំខាន់ ករណីនេះអនុផលជារឿយៗត្រូវបាន វាស់វែងតាម តម្លៃសុទ្ធ ដែលគួរឱ្យទុកចិត្តបានហើយតម្លៃនេះត្រូវបានកាត់ចេញពី ថ្លៃដើម ផលិតផលចម្បង។ ជាលទ្ធផល តម្លៃពិតគណនេយ្យរបស់ផលិតផលចម្បង មិនខុសគ្នាឆ្ងាយពីថ្លៃដើមរបស់វា។ ថ្លៃដើមរបស់សន្និធិអ្នកផ្តល់សេវាកម្មថ្លៃដើមនៃកសិផលដែលបានពីការប្រមូលពីទ្រព្យសកម្មជីវសាស្ត្របច្ចេកទេសសម្រាប់ប្រើក្នុងការវាស់វងថ្លៃដើមវិធីសាស្ត្រការគណនាថ្លៃដើមសន្និធិ។ រាល់ចំណុចសំខាន់ទាំងអស់ត្រូវបានបង្ហាញនៅជំពូកទី២ ជំពូកទី៣ និងជំពូកទី៤ បន្ទាប់ពីធ្វើការវិភាគ ទៅលើកិច្ចការដែលកំពុងអនុវត្តរបស់ក្រុមហ៊ុនក្នុង ប្រទេសកម្ពុជាយើងរួមទាំងទទួលបាន ការណែនាំពីគណនេយ្យករ និង អនុវត្តតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២ គឺទទួលបានសមិតិ

ផលល្អ និងក្នុងការស្វែងយល់ និងអាចធ្វើការវិភាគគ្រប់ជ្រុងជ្រោយ ដើម្បីវាយតម្លៃលើចំណុចខ្លាំង និងចំណុចខ្សោយ ហើយយើងសង្កេតឃើញការទាក់ទងទៅនិងដំណើរការផ្តល់ផលប្រយោជន៍របស់ក្រុមហ៊ុន ឬស្ថាប័ន ដែលធ្វើការប្រើប្រាស់ស្តង់ដាគណេនេយ្យអន្តរជាតិនៃកម្ពុជា២ គឺទទួលបានការរីកចម្រើនយ៉ាង ខ្លាំង និងទទួលបានភាពជឿជាក់របស់គណេនេយ្យករដែលកំពុងប្រើប្រាស់នៅក្នុងក្រុមហ៊ុន អ្វីៗគឺរៀបចំស្របទៅតាមបទដ្ឋានលិខិតប្រើប្រាស់ប្រចាំថ្ងៃគឺមានលក្ខណៈច្បាស់លាស់ត្រឹមត្រូវ ហើយចំណុចដែលសំខាន់ គ្រប់គ្រងបានការការពារពីការក្លែងបន្លំ ផ្តល់គុណតម្លៃដល់ក្រុមហ៊ុនបន្ថែម ផ្តល់ទំនុកចិត្តដល់អ្នកប្រើប្រាស់ខាងក្រៅ។ ទោះបីជាស្តង់ដានេះ អនុញ្ញាតឱ្យប្រើរូបមន្ត (ចូលមុនចេញមុន) និង(ថ្លៃដើមមធ្យម) ក៏ដោយ ការអនុញ្ញាតនេះអាចនាំឱ្យមាន ភាពខុសគ្នាក្នុងការរាយការណ៍ចំណេញ រវាងក្រុមហ៊ុនដែលប្រើវិធីសាស្ត្រផ្សេងគ្នា ជាពិសេសនៅពេលដែលតម្លៃទំនិញមានការប្រែប្រួលខ្លាំងអាចធ្វើឱ្យភាពប្រៀបធៀបគ្នានៅតែមានកម្រិតខ្លះ។ ការកំណត់ថ្លៃដើមសន្និធិអាចមានភាពស្មុគស្មាញ ជាពិសេសសម្រាប់ក្រុមហ៊ុនផលិតកម្មដែលមានថ្លៃចំណាយច្រើនប្រភេទ (ផ្ទាល់ ប្រយោល ថេរ និងប្រែប្រួល)។ ការប៉ាន់ស្មាន តម្លៃសុទ្ធគួរអោយទុកចិត្តបានក៏ទាមទារការវិនិច្ឆ័យ និងការប៉ាន់ស្មានច្រើនដែលអាចមានភាពមិនច្បាស់លាស់ និងអាចរងឥទ្ធិពលពីការលំអៀងរបស់អ្នកគ្រប់គ្រង។ ការអនុវត្តតាមតម្រូវការលម្អិតរបស់ស្តង់ដានេះ (ដូចជាការតាមដានថ្លៃដើម ការវាយតម្លៃ តម្លៃសុទ្ធគួរអោយទុកចិត្តបានជាប្រចាំ និងការលាតត្រដាងព័ត៌មាន) អាចទាមទារ ប្រព័ន្ធគណនេយ្យដ៏រឹងមាំ និង ធនធានច្រើន ជាពិសេសសម្រាប់អាជីវកម្មខ្នាតតូច និងមធ្យម។ សរុបមកវិញបន្ទាប់ពីការសិក្សាស្រាវជ្រាវទៅលើ សារៈសំខាន់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា២ រួចរាល់ និងឆ្លងតាមការប្រៀបធៀបជាមួយការសិក្សាតាមបែបទ្រឹស្តីមានលក្ខណៈល្អប្រសើរហើយទទួលបាន លទ្ធផលយ៉ាងល្អក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និង ស្ថាប័នរបស់គណនេយ្យករ និងក្រុមហ៊ុនដែលកំពុងប្រើប្រាស់ រួមជាមួយនៃការកើនឡើងខ្ពស់នៃការប្រើប្រាស់ស្តង់ដាគណនេយ្យនេះដែរ។ ដែលកំពុងវាយលុកខ្លាំងជាពិសេសម្ចាស់អាជីវកម្មងាកមកចាប់អារម្មណ៍ស្តង់ដាគណនេយ្យ ដែលបញ្ជាក់ពីការរីចម្រើន យើងអាចសន្និដ្ឋានបានថាស្តង់ដាគណនេយ្យអន្តរជាតិលេខ២ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ក្រុមហ៊ុន និង ស្ថាប័នហើយបានការពារពីហានិភ័យផ្សេងៗជាច្រើនទៀត អាចធ្វើឱ្យកម្ពុជាអាចប្រើប្រាស់ជាមួយនឹងពលរដ្ឋជាក់ស្តែង និងអនុវត្តយ៉ាងទូលំទូលាយ។

## ៥.២ ការផ្តល់អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សា និងបកស្រាយលើការសារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា២ ក៏មានចំណុចល្អប្រសើរជាច្រើនដែលអាចធ្វើអោយមាន ការប្រើប្រាស់កាន់តែច្រើន នាពេលបច្ចុប្បន្ន។ ផ្ទុយទៅវិញ ក៏មានចំណុចខ្វះខាតមួយចំនួនដែលគួរយកចិត្តទុកដាក់ ដើម្បីកែលម្អដើម្បីជាជំនួយកាន់តែ មានប្រសិទ្ធភាពល្អ ប្រសើរយើងខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួនដូចខាងក្រោម ៖

-ជ្រើសរើសវិធីសាស្ត្រដែលសមរម្យនឹងប្រភេទអាជីវកម្ម

-ប្រសិនបើសារពើភណ្ឌមានការប្រែប្រួលតម្លៃជាញឹកញាប់ ឬជាពាណិជ្ជកម្មមានការផ្លាស់ប្តូរខ្ពស់ គួរប្រើ FIFO ដើម្បីបង្ហាញភាពត្រឹមត្រូវនៃបរិមាណ និងតម្លៃសារពើភណ្ឌនៅក្នុងពេលបច្ចុប្បន្ន

-ប្រសិនបើមានការប្រើប្រាស់សារពើភណ្ឌមិនអាចបែងចែកនៃការទិញនីមួយៗបាន គួរប្រើ Cost Average ដែលផ្តល់ភាពស្មើគ្នាស្រួលក្នុងការគណនាតម្លៃសារពើភណ្ឌសរុប។

-រៀបចំប្រព័ន្ធគ្រប់គ្រងសារពើភណ្ឌអោយមានប្រសិទ្ធភាព

-ដំឡើងប្រព័ន្ធកំណត់ត្រាដែលអាចបង្ហាញភាពច្បាស់លាស់ពីការចូលចេញនៃសន្និធិ

-ជានាព័ត៌មានត្រឹមត្រូវសម្រាប់សារពើភណ្ឌក្នុងរបាយការណ៍ហិរញ្ញវត្ថុ

-តម្លៃសារពើភណ្ឌត្រូវតែស្ទង់យកតាមប្រភពដែលអាចជឿទុកចិត្តបាន

-បង្ហាញបែបផែនគណនីឱ្យច្បាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

-គ្រប់គ្រងការថែរក្សានិងបញ្ជីសារពើភណ្ឌប្រចាំឆ្នាំដោយប្រើ ជាការផ្ទៀងផ្ទាត់ជាក់ស្តែងនៃបរិមាណ និងលក្ខខណ្ឌនៃវត្ថុដែលផ្ទុកនៅក្នុងសារពើភ័ណ្ឌ ឬឃ្លាំង។

# ឯកសារយោង


1. thmeythmey. (2016, December 24). *និយមន័យស្តង់ដា*. Retrieved from https://thmeythmey.com/detail/47825
2. Videos Learning. (2023, February 15). *និយមន័យស្តង់ដា*. Retrieved from https://videoslearning.com/1-2887/
3. RIETI. (2021, April 19). *ប្រវត្តិនៃស្តង់ដា*. Retrieved from https://www.rieti.go.jp/en/columns/a01_0641.html
4. Foster Capital: *ទស្សនៈនៃស្តង់ដារ*. Retrieved July, 03 2025 from https://fastercapital.com/startup-topic/Importance-of-Standardization.html
5. Investopedia. Jason Fernando. (2025, October 05). *និយមន័យគណនេយ្យ*. Retrieved from https://www.investopedia.com/terms/a/accounting.asp
6. Collins. *និយមន័យគណនេយ្យ*. Retrieved July, 03 2025 from https://www.collinsdictionary.com/dictionary/english/accounting
7. AcBS. FRAS. *និយមន័យស្តង់ដារគណនេយ្យ*. Retrieved July, 03 2025 from https://www.frascanada.ca/en/acsb/about/what-are-accounting-standards#:~:text=Accounting%20standards%20are%20authoritative%20standards,and%20disclosed%20in%20financial%20statements
9. ClearTax. (2025, May 8). Accounting standards. ClearTax. https://cleartax.in/s/accounting-standards
10. Khatabook. (n.d.). *What Is Accounting Theory in Financial Reporting?* Khatabook. Retrieved November 21, 2025, from https://khatabook.com/blog/basic-accounting-theories/
11. Indeed Editorial Team. (2025, June 6). *Guide to accounting standards: Definition, types and uses*. Indeed. Retrieved November 21, 2025, from https://www.indeed.com/career-advice/career-development/accounting-standards
12. ACCA. (n.d.). *The history of how humans invented accounting*. ACCA. Retrieved November 21, 2025, from https://www.accaglobal.com/lk/en/study-with-acca/blog/how-humans-invented-accounting.html
13. CommerceMates. (n.d.). *Meaning and importance of accounting standards*. CommerceMates. Retrieved November 21, 2025, from https://commercemates.com/meaning-importance-of-accounting-standards/
14. Indeed Editorial Team. (2025, June 6). *What is financial reporting? Definition, types and importance*. Indeed. Retrieved November 21, 2025, from https://www.indeed.com/career-advice/career-development/what-is-financial-reporting
15. Coetsee, D. (2010). *The role of accounting theory in the development of accounting principles*. *Meditari Accountancy Research, 18*(1), 1–16. https://doi.org/10.1108/10222529201000001
16. Sokchea Pheourk. (2018, September 18). *តើអ្វីទៅជា "ទ្រព្យសកម្ម ឬ Active Asset" ?* Math and Money Academy. Retrieved November 21, 2025, from https://mathnmoney.blogspot.com/2018/09/active-asset.html
17. Financial statement. (n.d.). *In Wikipedia*. Retrieved November 21, 2025, from https://en.wikipedia.org/wiki/Financial_statement
18. Buy Khmer Book. (2021, August 23). [illegible] ? Buy Khmer Book. Retrieved November 21, 2025, from https://buykhmerbook.com/archives/105342

19. Investopedia. (n.d.). *What is an asset? Definition, types, and examples*. Retrieved November 21, 2025, from https://www.investopedia.com/terms/a/asset.asp
20. Pomelo-Paradigm. (2023, October 19). *The story of financial reporting*. Pomelo-Paradigm. Retrieved November 21, 2025, from https://www.pomelo-paradigm.com/story-financial-reporting-urd/
21. EnKash. (2025, October 30). *Financial statements: Meaning, importance, benefits, scope and objectives*. EnKash. Retrieved November 21, 2025, from https://www.enkash.com/resources/blog/financial-statements-meaning-importance-benefits-scope-and-objectives/
22. Osianor, E. (n.d.). *Theory of assets in accounting* (20 pp.). Retrieved November 21, 2025, from https://www.academia.edu/10948664/THEORY_OF_ASSETS_IN_ACCOUNTING
23. Pomelo-Paradigm. (2023, October 19). *The story of financial reporting*. Pomelo-Paradigm. Retrieved November 21, 2025, from https://www.pomelo-paradigm.com/story-financial-reporting-urd/
24. Ampong, M. (2023, April 15). *A brief history of "assets": How our perception of value has changed*. Maxwell Investments Group. Retrieved November 21, 2025, from https://maxwellinvestmentsgroup.com/2023/04/a-brief-history-of-assets-how-our-perception-of-value-has-changed/